ក្រសួងកិច្ចការនារី



# ដំណើរឆ្ពោះទៅមុខ

# សេចក្តីសង្ខេប

## ការប៉ាន់ប្រមាណអំពីយេនឌ័រនៅកម្ពុជា

២០១៤

រូបភាពគំរបមុខ៖

**ពីន ម៉ានីកា** (២៥ឆ្នាំ) ជាអ្នកស្រាវជ្រាវ និងជាអ្នកសម្របសម្រួលសរសេរនិក្ខេបបទផ្នែក ប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគមន៍ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ។ ម៉ានីកាសង្ឃឹមថានឹងបង្កើនចំណេះដឹងរបស់នាង ដើម្បីជួយដល់ប្រទេសជាតិ ។

**រិទ្ធី ជាតាណា** (២៦ឆ្នាំ) ជាប្រធានផ្នែកទីផ្សារនៅរោងភាពយន្តផ្កាទីនៀម និងជាគ្រូបង្រៀន ក្រៅម៉ោងនៅផ្នែកប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគមន៍ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ។ ជាតាណា ស្រឡាញ់ការងាររបស់នាង ហើយនាងសង្ឃឹមថា ថ្ងៃណាមួយ នាងនឹងអាចបើក អាជីវកម្មបានដោយខ្លួនឯង ។

# អារម្ភកថា

ក្រសួងកិច្ចការនារីមានមោទនភាពក្រៃលែងដោយបានរៀបចំឯកសារ ការប៉ាន់ប្រមាណយេនឌ័រ នៅកម្ពុជា (CGA) ឆ្នាំ២០១៤ ដែលមានចំណងជើងថា "ដំណើរឆ្ពោះទៅមុខដើម្បីសមភាពយេនឌ័រ និងភាពអង់អាចសម្រាប់ស្ត្រី" ដើម្បីវាស់វែងការអនុវត្តន៍គោលនយោបាយស្តីពីការលើកកម្ពស់សមភាពយេនឌ័រ និងការផ្តល់ភាពអង់អាចដល់ស្ត្រីរបស់រាជរដ្ឋាភិបាលកម្ពុជា និងបំពេញតម្រូវការ ក្នុងការរៀបចំគោលនយោបាយ កម្មវិធី របស់ក្រសួងស្ថាប័នតាមវិស័យ ។

ឯកសារប៉ាន់ប្រមាណយេនឌ័រនៅកម្ពុជាដែលមានការបង្ហាញអំពីទិដ្ឋភាពទូទៅនៃស្ថានភាពយេនឌ័រលើគ្រប់វិស័យ ត្រូវបានរៀបចំឡើងដោយក្រសួងកិច្ចការនារីចំនួន២លើករួចមកហើយលើក ទី១នៅឆ្នាំ២០០៤ លើកទី២នៅឆ្នាំ២០០៨ និងលើកទី៣នៅឆ្នាំ២០១៤ នេះ ក្រោមកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងមានការពិគ្រោះយោបល់យ៉ាងទូលំទូលាយជាមួយអ្នកពាក់ព័ន្ធក្នុងក្រសួងស្ថាប័ន តាមរយៈក្រុមការងារបច្ចេកទេសយេនឌ័រ។

ឯកសារការប៉ាន់ប្រមាណយេនឌ័រនៅកម្ពុជាឆ្នាំ២០១៤នេះ ត្រូវបានរៀបចំឡើងស្របពេលជាមួយការរៀបចំផែនការយុទ្ធសាស្ត្រនារីរតនៈទី៤ (២០១៤-២០១៨) របស់ក្រសួងកិច្ចការនារី។ ទទ្បីករណ៍ និងអនុសាសន៍ពាក់ព័ន្ធនឹងយេនឌ័រសំខាន់ៗក្នុង CGA ត្រូវបានបញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រនារីរតនៈ ដើម្បីបំរើផលប្រយោជន៍ និងឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងនៅពេលបច្ចុប្បន្នរបស់ស្ត្រី។

ការប៉ាន់ប្រមាណយេនឌ័រលើកទី៣នេះ បានបង្ហាញអំពីសមិទ្ធផលជាច្រើនដែលកម្ពុជា ទទួលបានក្នុងរយៈពេល៥ឆ្នាំកន្លងមក ដូចជា៖ ការថយចុះនៃចំនួនស្ត្រីក្នុងការងារដែលងាយរងគ្រោះនិងការងារគ្មានប្រាក់កម្រៃការកើនឡើងនៃចំនួនស្ត្រីដែលធ្វើការងារមានកម្រៃ និងប្រកបអាជីវកម្មដោយខ្លួនឯង ។ លើសពីនេះ អត្រាមរណៈភាពមាតាត្រូវបានកាត់បន្ថយជាងពាក់កណ្តាល អត្រាឆ្លងនៃមេរោគអេដស៍មានការធ្លាក់ចុះហួសពីការកំណត់ការកើនឡើងនូវការយល់ដឹងអំពីអំពើហិង្សាដែលទាក់ទងនឹងយេនឌ័រ និងគោលនយោបាយពាក់ព័ន្ធ ព្រមទាំងការសម្រេចបាននូវការបង្កើនសមាមាត្រស្ត្រីក្នុងជួរមន្ត្រីរាជការតាមការកំណត់។ នៅកម្រិតគោលនយោបាយ រាជរដ្ឋាភិបាលបានរៀបចំផែនការសកម្មភាពជាតិ

ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីលើកទី១ និងលើកទី២ និងផែនការពន្លឿនគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ដែលជាមូលដ្ឋានដើម្បីបន្តអនុវត្តសកម្មភាពឱ្យមានប្រសិទ្ធភាព និងនិរន្តរភាព តទៅអនាគត។

ទន្ទឹមនឹងនេះ CGA ក៏បានគូសបញ្ជាក់អំពីបញ្ហាប្រឈមមួយចំនួន និងផ្តល់នូវអនុសាសន៍ និងការណែនាំផងដែរនៅកម្រិតគោលនយោបាយសម្រាប់ក្រសួងកិច្ចការនារី និងអ្នករៀបចំគោលនយោបាយ ក្នុងក្រសួងពាក់ព័ន្ធ ដើម្បីពង្រឹងកិច្ចខិតខំប្រឹងប្រែងរួមគ្នាលើការលើកកម្ពស់សមភាពយេនឌ័រ និងផ្តល់ភាពអង់អាចដល់ស្ត្រី។ អនុសាសន៍ទាំងអស់នេះត្រូវបានឆ្លុះបញ្ចាំងនៅក្នុងផែនការយុទ្ធសាស្ត្រ នារីរតនៈទី៤ ដែលត្រូវបានរៀបចំឡើងសម្រាប់គាំទ្រដល់ការផ្លាស់ប្តូរយុទ្ធសាស្ត្ររបស់ក្រសួងកិច្ចការនារី ពីការអនុវត្តន៍សកម្មភាពជាលក្ខណៈគម្រោងតូចៗ ទៅជាលក្ខណៈអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី ពីការអនុវត្តន៍និងការផ្តល់សេវារបស់ក្រសួងកិច្ចការនារី ទៅជាការបញ្ជ្រាបយេនឌ័រទៅក្នុងគោលនយោបាយ និងកម្មវិធីរបស់រាជរដ្ឋាភិបាលទាំងមូល ឈានទៅលើកកម្ពស់គណនេយ្យភាពសង្គមសម្រាប់ស្ត្រី។

ក្រៅពីនេះ សន្ទុះនៃកំណើនសេដ្ឋកិច្ចរបស់កម្ពុជាដែលកំពុងឈានទៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាប ក៏បានបង្កឱ្យមានផងដែរនូវការកើនឡើងនៃវិសមភាព និងភាពងាយរងគ្រោះចំពោះប្រជាពលរដ្ឋក្នុងតំបន់ដែលខ្វះខាតសេវា។ ដោយសារមូលហេតុនេះ CGA ឆ្នាំ២០១៤ និងផែនការយុទ្ធសាស្ត្រនារីរតនៈទី៤ បានបញ្ជ្រាបប្រកបដោយការយកចិត្តទុកដាក់នូវបញ្ហាទាំងឡាយដែលក្រុមងាយរងគ្រោះជួបប្រទះ រួមទាំងវិធានការសមស្របសម្រាប់ដំណោះស្រាយ។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ SIDA, UNDP, UNFPA, UN WOMEN, UNESCO, UNICEF, ADB, Australian Aid/DFAT, GIZ/CIM, JICA, Swiss Agency for Development and Cooperation ( SDC ), Oxfam GB, Fred Hollows Foundation, Plan International និងដៃគូផ្សេងៗទៀត ដែលបានឧបត្ថម្ភនិងចូលរួមក្នុងការរៀបចំឯកសារCGA ព្រមទាំងកិច្ចសហការផ្សេងៗទៀតក្នុងការលើកកម្ពស់សមភាពយេនឌ័រនៅកម្ពុជា ។

បំណងប្រាថ្នារបស់យើងខ្ញុំគឺធ្វើយ៉ាងណាឱ្យអ្នករៀបចំបង្កើតគោលនយោបាយ ផែនការ កម្មវិធី និងអ្នកធ្វើសេចក្តីសម្រេចនៅគ្រប់វិស័យ យល់ច្បាស់អំពីបញ្ហាយេនឌ័រនិងអនុសាសន៍ពាក់ព័ន្ធ ដោយក្រសួងស្ថាប័នតាមវិស័យទាំងនោះមានតួនាទីយ៉ាងសំខាន់ក្នុងការរក្សា

និរន្តរភាពនៃការវិវត្តន៍របស់សង្គមឆ្ពោះទៅមុខដើម្បីសមភាពយេនឌ័រ។

ក្រសួងកិច្ចការនារីសង្ឃឹមយ៉ាងមុតមាំថា រាល់ការរៀបចំគោលនយោបាយ កម្មវិធី ការផ្តល់សេវា និងការអនុវត្តន៍គម្រោងក្នុងគ្រប់វិស័យ នឹងឆ្លើយតបទៅនឹងបញ្ហានិងអនុសាសន៍ទាំងឡាយដែលមាននៅក្នុងឯកសារប៉ាន់ប្រមាណយេនឌ័រនៅកម្ពុជា និងផែនការយុទ្ធសាស្ត្រនារីរតនៈទី៤។ នេះគឺជាគន្លឹះសម្រាប់ការបញ្ជ្រាបយេនឌ័រប្រកបដោយប្រសិទ្ធភាព និងការធ្វើឱ្យមានចំណែកស្មើភាពសម្រាប់នារីនៅកម្ពុជា។

*រាជធានីភ្នំពេញ ខែធ្នូ ឆ្នាំ២០១៤*

**វេជ្ជ. អ៊ឹង កន្ថាផាវី**
**រដ្ឋមន្ត្រី ក្រសួងកិច្ចការនារី**

# សេចក្ដីថ្លែងអំណរគុណ

ការប៉ាន់ប្រមាណយេនឌ័រនៅកម្ពុជាត្រូវបានចងក្រងឡើងនៅក្រោមការដឹកនាំ និងសម្របសម្រួលដោយក្រសួងកិច្ចការនារី ដោយមានការគាំទ្រនិងរួមចំណែកពីក្រសួងស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិល។ ក្រសួងកិច្ចការនារីសូមសំដែងនូវសេចក្ដីថ្លែងអំណរគុណជូនចំពោះលោកជំទាវ ឯកឧត្តម លោក លោកស្រី ដែលបានចូលរួមចំណែកក្នុងការរៀបចំឯកសារនេះ ដូចតទៅ៖

**ក្រុមការងាររៀបចំការប៉ាន់ប្រមាណយេនឌ័រនៅកម្ពុជា** ទទួលខុសត្រូវលើដំណើរការរៀបចំឯកសារទាំងមូល ក្រោមការដឹកនាំរបស់ **លោកជំទាវ វេជ្ជបណ្ឌិត អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ។ ក្រុមការងារមានលោកជំទាវ ឃឹម ចំរើន រដ្ឋលេខាធិការជាប្រធាន និងគាំទ្របច្ចេកទេសដោយដោយផ្ទាល់ពីលោកជំទាវ កេត សំអាត ទីប្រឹក្សាជាន់ខ្ពស់ក្រសួងកិច្ចការនារី លោជំទាវ គឹម ស៊ីផាត់ អគ្គនាយិកា ក្រសួងកិច្ចការនារី និង លោក ថេ ឈុន ហាក់ អគ្គនាយករងក្រសួងកិច្ចការនារី លោកស្រី ញាណ សុចិត្រា ប្រធាននាយកដ្ឋានសមភាពយេនឌ័រ លោកស្រី តែ រួចលីម ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ និងសមាជិកផ្សេងៗទៀតមកពីនាយកដ្ឋានបច្ចេកទេសនានាចំណុះក្រសួងកិច្ចការនារី។ ក្រុមការងារមានការគាំទ្រផ្នែក បច្ចេកទេសពីគម្រោង **ភាពជាដៃគូដើម្បីសមធម៌យេនឌ័រ** (PGEIII) ដែលមានលោកស្រី Mia Hyun ជាទីប្រឹក្សាជាន់ខ្ពស់ប្រចាំក្រសួងកិច្ចការនារីជាអ្នកសម្របសម្រួលទូទៅគាំទ្រដោយក្រុមអ្នកជំនាញតាមវិស័យរបស់គម្រោង រួមមានលោកស្រី ឌី ម៉ានី លោក ប៉ែន បូរី លោកស្រី ហេង សិលទិ លោក ឈន ថាវរិទ្ធិ និង លោក គឹម សុពណ៌។ **ក្រុមការងារបច្ចេកទេសយេនឌ័រ** (TWG-G) បានផ្ដល់ជាវេទិកាដ៏សំខាន់ក្នុងការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងក្រុមអ្នកជួយកែសម្រួល (peer reviewers) ដែលជាអ្នកជំនាញមកពីក្រសួងកិច្ចការនារី ក្រសួងពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិលបានជួយពិនិត្យឡើងវិញលើសេចក្ដីព្រាងតាមជំនាញពាក់ព័ន្ធ។ បច្ចេកទេសទាក់ទងនឹងរូបភាព ការរចនា និងសម្ភារៈសម្រាប់ផ្សព្វផ្សាយផ្ដល់ដោយ Good Morning Beautiful ។

**ក្រុមអ្នកដឹកនាំនិងរៀបចំជំពូកទី១៖** ជំពូកនេះដឹកនាំរៀបចំដោយលោកជំទាវ ឃឹម ចំរើន លោក ថេ ឈុនហាក់ និង លោកស្រី ញាណ សុចិត្រា ដោយមានជំនួយបច្ចេកទេសក្នុងការសិក្សាស្រាវជ្រាវនិងធ្វើបច្ចុប្បន្នភាពពីអ្នកជំនាញនៃគម្រោង PGE III រួមមាន៖

លោក ប៉ែន បូរី និង លោក ឈន ថាវរិទ្ធិ៍ ក្រោមការគាំទ្រនិងផ្តល់យោបល់ពី លោកស្រី Mia Hyun និងជំនួយបច្ចេកទេសពីលោកស្រី Loksee Leung លោក គឹម សុពណ៌ និងលោកស្រី កង វិរិយ៉ា។

**ក្រុមអ្នកដឹកនាំនិងរៀបចំជំពូកទី២៖** ជំពូកនេះដឹកនាំរៀបចំដោយលោកជំទាវ ហ៊ូ សាមិត្ត និងចងក្រងសេចក្តីព្រាងដោយលោកស្រី Kasumi Nakagawa ក្រោមការឧបត្ថម្ភរបស់ UNDP/PGE ដោយមានការផ្តល់ជាតុចូលពីនាយកដ្ឋានបច្ចេកទេសពាក់ព័ន្ធរបស់ក្រសួងកិច្ចការនារី ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី និងក្រសួងអប់រំ យុវជន និងកីឡា។ ជំនួយបច្ចេកទេសទូទៅផ្តល់ដោយលោក គឹម សុពណ៌ ។

**ក្រុមអ្នកដឹកនាំនិងរៀបចំជំពូកទី៣៖** ជំពូកនេះដឹកនាំរៀបចំដោយលោកជំទាវ ច័ន្ទ សូរិយ៍ និងចងក្រងសេចក្តីព្រាងដោយលោកស្រីសាស្ត្រាចារ្យ Fiona MacPhail ដែលជាទីប្រឹក្សារបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងផ្តល់ជាតុចូលនិងកែសម្រួលដោយលោកស្រី ប៊ុនឈិត វាសនា ប្រធាននាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចនៃក្រសួងកិច្ចការនារី និងក្រុមការងារ រួមមាន លោកស្រី សុត ស៊ីថុន លោកស្រី ហេង សិលទិ កញ្ញា ជឿន សមនា និងលោក Udo Gartner ។ ជាតុចូលស្តីពីទេសន្តប្រវេសន៍ផ្តល់ដោយលោកស្រី Jenna Holliday (UN WOMEN) និងជាតុចូលពាក់ព័ន្ធនឹងវិស័យកសិកម្មផ្តល់ដោយលោក Emmanuel Santoyo Rio ទីប្រឹក្សារបស់ធនាគារពិភពលោក។ លោកស្រី Karin Schelzig (ADB) ជាអ្នកផ្តល់ជាតុចូលផ្នែកបច្ចេកទេសកែសម្រួល និងពិនិត្យជារួមលើខ្លឹមសារ។ លោកស្រី ជា ចាន់ឌី ដែលជាអ្នកឯកទេសយេនឌ័ររបស់ ADB ផ្តល់ការគាំទ្រក្នុងការសិក្សាស្រាវជ្រាវ ។

**ក្រុមអ្នកដឹកនាំនិងរៀបចំជំពូកទី៤៖** ជំពូកនេះដឹកនាំរៀបចំដោយលោកជំទាវ ខេង សំវ៉ាដា និងលោកជំទាវ អ៊ឹម ស៊ីថៃ និងសរសេរសេចក្តីព្រាងដោយលោកស្រី Maki Hayashikawa (UNESCO Paris) និងលោក Santosh Khatri (UNESCO Phnom Penh) ឧបត្ថម្ភដោយ UNICEF និង UNESCO ដោយមានការផ្តល់ជាតុចូលពី ឯកឧត្តម ណាត ប៊ុនរឿន រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា លោកស្រី ឡុង និមល អគ្គនាយិកាក្រសួងកិច្ចការនារី លោកស្រី នុំ បូផារី ប្រធាននាយកដ្ឋានស្ត្រីនិងការអប់រំនៃក្រសួងកិច្ចការនារី លោក តឹប អឿន មន្ត្រីជំនាញមកពីក្រសួងការងារ និងបណ្តុះបណ្តាល

វិជ្ជាជីវៈ លោកស្រី Erika Boak (UNICEF) លោកស្រី Lisa Kim (UNICEF) លោកស្រី Naomi Neijhoft (UNICEF) លោក សុទ្ធ និមល (UNESCO) និង លោកស្រី ឯក សុផាណា (Plan International)។

**ក្រុមអ្នកដឹកនាំនិងរៀបចំជំពូកទី៥៖** ជំពូកនេះដឹកនាំរៀបចំដោយ លោកជំទាវ កុប ម៉ារីយ៉ាស់ រដ្ឋលេខាធិការក្រសួងកិច្ចការនារីនិង លោកជំទាវ ពេជ ពិទូរ្យរដ្ឋា អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី និងចងក្រងសេចក្តីព្រាងដោយលោកស្រីបណ្ឌិត Kate Frieson ក្រោមការឧបត្ថម្ភពីអង្គការ UNFPA ផ្តល់ធាតុចូលដោយ លោកស្រី ហ៊ូ និរមិត្តា លោកស្រី គូ សុទ្ធា លោកស្រី ឡេង មោនីភាព លោកស្រី ហ៊ូ សុផល្លិកា លោកស្រី សេងផល ដាវីន លោកស្រីសាស្ត្រាចារ្យ វេជ្ជ. ទុង រដ្ឋាវី ប្រធានមជ្ឈមណ្ឌលជាតិគាំពារមាតានិងទារកនៃក្រសួងសុខាភិបាលលោកស្រី Sarah Knibbs (UNWOMEN) និង លោកស្រី អាំង សុខរើន (UNFPA) ព្រមទាំងស្ថាប័ន និងអង្គការដៃគូពាក់ព័ន្ធជាច្រើនទៀត។

**ក្រុមអ្នកដឹកនាំនិងរៀបចំជំពូកទី៦៖** ជំពូកនេះដឹកនាំរៀបចំដោយ លោកជំទាវ កុប ម៉ារីយ៉ាស់ រដ្ឋលេខាធិការក្រសួងកិច្ចការនារី និង លោកជំទាវ ពេជ ពិទូរ្យរដ្ឋា អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី និងចងក្រងសេចក្តីព្រាងដោយលោកស្រីបណ្ឌិត Silja Rajander (UN Women) ផ្តល់ធាតុចូលដោយ លោកស្រី ហ៊ូ និរមិត្តា និងក្រុមការងាររបស់នាយកដ្ឋានស្ត្រី និងសុខភាព នៃក្រសួងកិច្ចការនារី លោកជំទាវ ស៊ឹម ខេងខាំ អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លោកស្រីវេជ្ជ. ងិន លីណា ប្រធាននាយកដ្ឋានផែនការតាមដាន វាយតម្លៃ និងស្រាវជ្រាវ នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ព្រមទាំងស្ថាប័ន និងអង្គការដៃគូពាក់ព័ន្ធជាច្រើនទៀត។

**ក្រុមអ្នកដឹកនាំនិងរៀបចំជំពូកទី៧៖** ជំពូកនេះដឹកនាំរៀបចំដោយ លោកជំទាវ ស៊ី ដេហ្វីន រដ្ឋលេខាធិការក្រសួងកិច្ចការនារី និងលោកជំទាវ ទេស ច័ន្ទសារឿន អនុរដ្ឋលេខាធិការក្រសួង កិច្ចការនារី ចងក្រងសេចក្តីព្រាងដោយលោកស្រី Robin Mauney ក្រោមការឧបត្ថម្ភពី Australian Aid/DFAT និងផ្តល់ធាតុចូលដោយ លោកជំទាវ ខៀវ សិរីវុឌ្ឍា អគ្គនាយិកាក្រសួងកិច្ចការនារី លោកស្រី សាខឿន សារ៉ាតឌី អគ្គនាយិការង លោកស្រី កេត ម៉ារឌី ប្រធាននាយកដ្ឋានការពារ ផ្លូវច្បាប់ និងគម្រោង Access to Justice for Women ។

**ក្រុមអ្នកដឹកនាំនិងរៀបចំជំពូកទី៨៖** ជំពូកនេះដឹកនាំរៀបចំដោយលោកជំទាវ ឃឹម ចំរើន រដ្ឋលេខាធិការក្រសួងកិច្ចការនារី និង លោកជំទាវ គឹម ស៊ីផាត់ អគ្គនាយិកាក្រសួងកិច្ចការនារី និងចងក្រងសេចក្ដីព្រាងដោយលោកស្រី Ingrid Quinn ក្រោមការឧបត្ថម្ភពីអង្គការ Oxfam GB ដោយមានជាតុចូលបន្ថែមពីលោកស្រី តែ វូចលីម ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ និងលោក ឈន ថាវរិទ្ធី លោក ថេ ឈុនហាក់ និង លោកស្រី ញាណ សុចិត្រា ។

**ក្រុមអ្នកដឹកនាំនិងរៀបចំជំពូកទី៩៖** ជំពូកនេះដឹកនាំរៀបចំដោយ លោកជំទាវ ខៀវ សិរីវុឌ្ឍា អគ្គនាយិកាក្រសួងកិច្ចការនារី និងចងក្រងសេចក្ដីព្រាងដោយ លោក Rodrigo Montero Cano ក្រោមការឧបត្ថម្ភពីក្រសួងសហប្រតិបត្តិការនិងអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ប្រទេសអាឡឺម៉ង់ (BMZ) និងក្រសួងសហប្រតិបត្តិការអន្តរជាតិនិងពាណិជ្ជកម្មនៃប្រទេសអូស្ត្រាលី (DFAT) ដោយមានការផ្តល់ជាតុចូលបន្ថែមពី DFAT, Plan International, HelpAge Cambodia, UNFPA, និងគម្រោង Cambodian Defenders.

**ក្រុមអ្នកដឹកនាំនិងរៀបចំជំពូកទី១០៖** ជំពូកនេះដឹកនាំរៀបចំដោយ លោកជំទាវ ស៊ីវណ្ណា បុទុម រដ្ឋលេខាធិការក្រសួងកិច្ចការនារី និងចងក្រងសេចក្ដីព្រាងដោយ លោក Udo Gartner កែសម្រួលដោយ លោកស្រី ជុត លាងវណ្ណី អគ្គនាយិកាក្រសួងកិច្ចការនារី លោកស្រី ចេង ជិនណោត អនុប្រធាននាយកដ្ឋានសមភាពយេនឌ័រ លោក សៅ ចាន់តូម៉ាលី លោក សុខ ពិសិទ្ធ លោកស្រី គឹម សុខ័ណ្ឌារី និង លោក ឈន ថាវរិទ្ធី។

# សេចក្តីផ្តើម

សេចក្តីសង្ខេបសម្រាប់គោលនយោបាយនៃការប៉ាន់ប្រមាណយេនឌ័រនៅកម្ពុជារួមមាន ១០ជំពូក ដែលតាក់តែងឡើងដោយក្រុមការងារក្រសួងកិច្ចការនារី។ ឯកសារនេះបង្ហាញអំពីព័ត៌មាន និងទិន្នន័យដែលមានបច្ចុប្បន្នភាពពាក់ព័ន្ធនឹងស្ថានភាពយេនឌ័រលើគ្រប់វិស័យនៅកម្ពុជា និងផ្តល់ព័ត៌មានសម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រនារីរតនៈទី៤ និងគោលនយោបាយពាក់ព័ន្ធនានា ។

សេចក្តីសង្ខេបសម្រាប់គោលនយោបាយទាំង១០ជំពូក រួមមាន៖

១. ការបញ្ជ្រាបយេនឌ័រ៖ បរិយាបទគោលនយោបាយ ស្ថាប័ន និងភាពដៃគូ
២. ទំនាក់ទំនង និងឥរិយាបថយេនឌ័រ
៣. ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចសម្រាប់ស្ត្រី
៤. យេនឌ័រក្នុងវិស័យអប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ
៥. យេនឌ័រ និងសុខភាព
៦. យេនឌ័រ និងមេរោគអេដស៍
៧. អំពើហិង្សាលើស្ត្រី និងក្មេងស្រី
៨. ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចក្នុងវិស័យសាធារណៈ និងនយោបាយ
៩. ក្រុមស្ត្រី និងក្មេងស្រីដែលងាយរងគ្រោះ
១០. យេនឌ័រ និងការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍន៍បៃតង និងការគ្រប់គ្រងគ្រោះមហន្តរាយ

សេចក្តីសង្ខេបសម្រាប់គោលនយោបាយ ទាំង១០ជំពូកនេះ ដកស្រង់ចេញពីឯកសារប៉ាន់ប្រមាណស្ថានភាពយេនឌ័រនៅកម្ពុជា ដែលឯកសារនេះបានរៀបចំឡើងដោយផ្អែកលើព័ត៌មានដែលផ្តល់ដោយក្រសួង ស្ថាប័ន និងដៃគូពាក់ព័ន្ធ រួមទាំងការវិភាគយេនឌ័រលើទិន្នន័យដែលបានមកពីអង្កេតនានារបស់ជាតិ ដូចជាអង្កេតចន្លោះជំរឿនប្រជាសាស្ត្រកម្ពុជា ឆ្នាំ២០១២ អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា ឆ្នាំ២០១២ អង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជា ឆ្នាំ២០១០ អង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១២ ជំរឿនសេដ្ឋកិច្ចកម្ពុជា ឆ្នាំ២០១១ និងការសិក្សាផ្សេងៗទៀតនៅតាមវិស័យ។ ការវិភាគលើអង្កេតថ្មីៗទាំងនេះ ធ្វើឡើងដោយ

មានការប្រៀបធៀបទៅនឹងអង្កេតមុនៗ និងបានផ្តល់នូវព័ត៌មានជាច្រើន ស្តីពីការប្រែប្រួលនៃសូចនាករយេនឌ័រសំខាន់ៗក្នុងរយៈពេលកន្លងមក។

ការប៉ាន់ប្រមាណស្ថានភាពយេនឌ័រនៅកម្ពុជា ក៏បានរួមបញ្ចូលនូវការពិនិត្យលើឯកសារគោលនយោបាយសំខាន់ៗ ជាពិសេសយុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាពនៃកម្ពុជា ដំណាក់កាលទី៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៤-២០១៨ ដែលផ្តល់នូវក្របខ័ណ្ឌសម្រាប់ការអនុវត្តយុទ្ធសាស្ត្រចតុកោណ និងដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា។

យោបល់សន្និដ្ឋានរបស់គណៈកម្មាធិការ CEDAW លើរបាយការណ៍លើកទី៤ និងទី៥ របស់កម្ពុជា ស្តីពីការអនុវត្តន៍អនុសញ្ញានេះសម្រាប់ឆ្នាំ២០១៣ ក៏បានលើកយកមកវិភាគនៅក្នុងសេចក្តីសង្ខេបសម្រាប់គោលនយោបាយនេះផងដែរ ដើម្បីលើកជាអនុសាសន៍សមស្រប។ សេចក្តីសង្ខេបនេះ បានពិនិត្យ និងកែសម្រួលតាមរយៈក្រុមការងារបច្ចេកទេសក្រសួងកិច្ចការនារី និងការពិគ្រោះយោបល់យ៉ាងទូលំទូលាយក្នុងក្របខណ្ឌក្រុមការងារបច្ចេកទេសយេនឌ័រ និងក្រសួងស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិល ។

សេចក្តីសង្ខេបនីមួយៗ រួមបញ្ចូលនូវសមិទ្ធផល បញ្ហាប្រឈម និងអនុសាសន៍សម្រាប់ឆ្លើយតបនឹងបញ្ហាដែលនៅសេសសល់តាមវិស័យនីមួយៗ។ របកគំហើញ និងអនុសាសន៍ទាំងនេះត្រូវបានប្រើប្រាស់ជាមូលដ្ឋាន ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រនារីរតនៈទី៤ ឆ្នាំ២០១៤-២០១៨។

សេចក្តីសង្ខេបនេះ ក៏បង្ហាញនូវទិដ្ឋភាពទូទៅនៃវឌ្ឍនភាពថ្មីៗ បញ្ហាប្រឈម និងអនុសាសន៍សំខាន់ៗ រួមទាំងបញ្ហាអន្តរវិស័យ ដូចជាការប្រែប្រួលទាក់ទងនឹងឥរិយាបថសង្គម និងការផ្តោតការយកចិត្តទុកដាក់លើក្រុមជនដែលងាយរងគ្រោះ ជាដើម។

# សេចក្ដីសង្ខេប

## ការបញ្ជ្រាបយេនឌ័រ៖ បរិបទគោលនយោបាយ ស្ថាប័ន និងភាពជាដៃគូ

ក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ រាជរដ្ឋាភិបាលកម្ពុជាបានបន្តបញ្ជ្រាបយេនឌ័រក្នុងគោលនយោបាយ ច្បាប់ ផែនការ និងកម្មវិធីនានារបស់ខ្លួន រួមទាំងការពង្រឹងសមត្ថភាពស្ថាប័ន និងភាពជាដៃគូជាមួយអ្នកពាក់ព័ន្ធ ដើម្បីកិច្ចអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាព និរន្តរភាពសម្រាប់ទាំងអស់គ្នា។ ទោះបីជាមានឧបសគ្គមួយចំនួនទាក់ទងនឹងសមត្ថភាព និងថវិកាក្នុងការបញ្ជ្រាបយេនឌ័រក៏ដោយ រាជរដ្ឋាភិបាលទទួលបាននូវសមិទ្ធិផលថ្មីៗជាច្រើនគួរឱ្យកត់សម្គាល់ និងបានប្រែក្លាយការបញ្ជ្រាបយេនឌ័រឱ្យកាន់តែមានលក្ខណៈស៊ីជម្រៅ និងជាប្រព័ន្ធក្នុងគ្រប់វិស័យ។

### សមិទ្ធផលសំខាន់ៗ

យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា ដំណាក់កាលទី៣ (២០១៣-២០១៨) ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាពនៅកម្ពុជា បានទទួលស្គាល់សមភាពយេនឌ័រថាជាគន្លឹះមួយនៃកិច្ចអភិវឌ្ឍន៍ជាតិនិងធនធានមនុស្ស។ រាជរដ្ឋាភិបាលបានបញ្ជាក់អំពីភាពចាំបាច់ក្នុងការកែលម្អ និងលើកស្ទួយស្ថានភាពស្ត្រី ដែលជាឆ្អឹងខ្នងនៃសង្គម និងសេដ្ឋកិច្ចជាតិ ។

រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តច្បាប់ក្នុងការការពារសិទ្ធិរបស់ស្ត្រីរួមមាន៖ ច្បាប់ស្ដីពីការបោះឆ្នោត (ឆ្នាំ១៩៩៧) ច្បាប់វិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោត (ឆ្នាំ២០១៣) ច្បាប់ស្ដីពីការងារ (ឆ្នាំ១៩៩៧) ច្បាប់ភូមិបាល (ឆ្នាំ២០០១) ច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ (ឆ្នាំ២០០៥) ច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ (ឆ្នាំ២០០៨) ក្រមរដ្ឋប្បវេណី (ឆ្នាំ២០០៧) ក្រមនីតិវិធីរដ្ឋប្បវេណី (ឆ្នាំ២០០៦) ក្រមព្រហ្មទណ្ឌ (ឆ្នាំ២០០៩) ក្រមនីតិវិធីព្រហ្មទណ្ឌ (ឆ្នាំ២០០៧) ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (ឆ្នាំ២០០៨) ច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (ឆ្នាំ២០០៨) និងច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ (ឆ្នាំ២០១១)។



▲ **លោកជំទាវ វេជ្ជបណ្ឌិត អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងមន្ត្រីវ័យក្មេង នៃក្រសួងកិច្ចការនារី

នៅឆ្នាំ២០១០ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព ដែលនៅក្នុងចំណោមវិធានការសំខាន់ៗ មានចំណុចដែលពាក់ព័ន្ធនឹងគ្មានអំពើហិង្សាក្នុងគ្រួសារ និងគ្មានការជួញដូរស្ត្រីនិងកុមារ។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០១៤-២០១៨) បានបញ្ចូលសូចនាករដែលទាក់ទងនឹងសមភាពយេនឌ័រ និងបានជំរុញបន្ថែមទៀតដល់ក្រសួងស្ថាប័ន ពាក់ព័ន្ធក្នុងការបញ្ជ្រាបយេនឌ័រនៅតាមវិស័យ ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្រ និងភាពងាយរងគ្រោះរបស់ស្ត្រី ជាពិសេសស្ត្រីពិការ និងស្ត្រីជនជាតិដើមភាគតិច។

សូចនាករត្រួតពិនិត្យរួមគ្នា (JMIs ២០១៤-២០១៨) ដែលទាក់ទងនឹងសមភាពយេនឌ័រ ត្រូវបានកំណត់រួមគ្នារវាងក្រសួងកិច្ចការនារី ជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ សម្រាប់វាស់វែង និងពង្រឹងគុណភាពនៃការបញ្ជ្រាបយេនឌ័រ និងការផ្តល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ។

ក្របខ័ណ្ឌពន្លឿនគោលដៅសហស្សវត្សរ៍ (MAF) ២០១២-២០១៥ ត្រូវបានបង្កើតឡើងដើម្បីពន្លឿនការសម្រេចបានតាមគោលដៅទី៣នៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាតាមរយៈ ១) ការពង្រឹងជំនាញវិជ្ជាជីវៈសម្រាប់ស្ត្រីដោយផ្អែកលើតម្រូវការទីផ្សារ ២) បង្កើតសហគ្រាសខ្នាតតូចនិងមធ្យម និង ៣) កែលម្អជីវភាពរស់នៅតាមតំបន់ជនបទ។

រាជរដ្ឋាភិបាលបានប្រើប្រាស់លទ្ធផលនៃការប៉ាន់ប្រមាណយេនឌ័រនៅកម្ពុជាឆ្នាំ២០០៨ សម្រាប់ការបញ្ជ្រាបយេនឌ័រ និងបានអនុវត្តយ៉ាងជោគជ័យនូវផែនការយុទ្ធសាស្ត្រនារីរតនៈទី៣ (២០០៩-២០១៣)។ បច្ចុប្បន្ន ការប៉ាន់ប្រមាណយេនឌ័រនៅកម្ពុជា (ឆ្នាំ២០១៤) និងផែនការយុទ្ធសាស្ត្រ នារីរតនៈទី៤ (២០១៤-២០១៨) កំពុងត្រូវបានរៀបចំដោយក្រសួងកិច្ចការនារី។ ឯកសារទាំងនេះ គឺជាមគ្គុទេសក៍ក្នុងការតាក់តែងគោលនយោបាយ ផែនការ និងកម្មវិធីនានាដើម្បីសមភាពយេនឌ័រ និងកិច្ចអភិវឌ្ឍន៍។

យេនឌ័រត្រូវបានបញ្ជ្រាបទៅក្នុងកម្មវិធីកំណែទម្រង់ជាតិសំខាន់ៗដូចជា កំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ នៅក្នុងកម្មវិធីជាតិ១០ឆ្នាំ សម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងផែនការអនុវត្ត៣ឆ្នាំដំបូង (ផអ៣) និងផែនការអនុវត្ត៣ឆ្នាំបន្ទាប់។

## បញ្ហាប្រឈម

- វិសមភាពយេនឌ័រនៅកម្ពុជាត្រូវបានវាស់វែងនៅក្នុងសន្ទស្សន៍វិសមភាពយេនឌ័រ (Gender Inequality Index-GII) ដែលផ្តោតលើសុខភាពបន្តពូជ ការផ្តល់ភាពអង់អាចដល់ស្ត្រី និងការចូលរួមក្នុងទីផ្សារការងារ ដោយកម្ពុជាជាប់ចំណាត់ថ្នាក់លេខ៩៦ ក្នុងចំណោមប្រទេសចំនួន១៤៨ (ឆ្នាំ២០១២)[1]។ ចំណែកឯក្នុងសន្ទស្សន៍គម្លាតយេនឌ័រសកល ដែលកំណត់គម្លាតយេនឌ័រថ្នាក់ជាតិលើលក្ខណៈវិនិច្ឆ័យផ្អែកសេដ្ឋកិច្ច នយោបាយ ការអប់រំ និងសុខភាព ក្នុងនោះពិន្ទុជារួមរបស់កម្ពុជាបានកើនឡើងពី០,៦២៩ ក្នុងឆ្នាំ២០០៦ ដល់០,៦៥២ ក្នុងឆ្នាំ២០១៤ ក៏ប៉ុន្តែកម្ពុជានៅមានចំណាត់ថ្នាក់ទាបនៅឡើយ ដោយស្ថិតក្នុងលំដាប់លេខ១០៨ ក្នុងចំណោម១៤២ប្រទេស (ឆ្នាំ២០១៤)[2]។ ។ ចំណាត់ថ្នាក់របស់កម្ពុជាពុំមាន

1 UNDP, Gender Inequality Index, http://hdr.undp.org/en/content/gender-inequality-index-gii

2 World Economic Forum, Global Gender Gap Index 2014, http://www.weforum.org/issues/global-gender-gap

ការប្រែប្រួលច្រើនឡើយ គឺក្នុងលំដាប់លេខ ៧៦-៧៧ (លេខ១០០ជាលំដាប់ទាបបំផុត និងលេខ១ជាលំដាប់ខ្ពស់បំផុត)។ ទាក់ទងនឹងឱកាសនិងការចូលរួមផ្នែកសេដ្ឋកិច្ច និងការទទួលបានការអប់រំ ពិន្ទុរបស់កម្ពុជាមានកម្រិតខ្ពស់ជាងមធ្យមបន្តិចក្នុងចំណោមប្រទេសដែលមានចំណូលប្រហាក់ប្រហែលប៉ុន្តែទាក់ទងនឹងការផ្តល់ភាពអង់អាចក្នុងផ្នែកនយោបាយ កម្ពុជាទទួលបានពិន្ទុក្រោមមធ្យម។

- សមត្ថភាពរបស់ក្រសួង ស្ថាប័ន ក្នុងការវិភាគ ការស្វែងរកការគាំទ្រមតិ និងការបញ្ជ្រាបយេនឌ័រឱ្យបានស៊ីជម្រៅនៅមានកម្រិត។
- ការអនុវត្តច្បាប់គោលនយោបាយផែនការនិងកម្មវិធីនានានៅមានគម្លាតនៅឡើយ។
- សកម្មភាពបញ្ជ្រាបយេនឌ័រនៅពុំទាន់បានប្រមូលផ្តុំជាលក្ខណៈអភិក្រមគ្រប់គ្រងទូទាំងកម្មវិធីនៅឡើយ។
- ការសម្របសម្រួលរវាងអ្នកពាក់ព័ន្ធ នៅមានកម្រិត។
- ទំនាក់ទំនងរវាងនាយកដ្ឋានជំនាញរបស់ក្រសួងកិច្ចការនារី ជាមួយក្រុមការងារបញ្ជ្រាបយេនឌ័រនៃក្រសួង ស្ថាប័ន ពាក់ព័ន្ធជាមួយក្រុមការងារបច្ចេកទេសផ្សេងៗទៀតនៅមានកម្រិត។
- ថវិកាសម្រាប់អនុវត្តសកម្មភាពបញ្ជ្រាបយេនឌ័ររបស់ក្រសួងស្ថាប័នពាក់ព័ន្ធនៅមានកម្រិត។
- ផ្នត់គំនិតរបស់ថ្នាក់ដឹកនាំក្រសួង ក៏ដូចជាបុគ្គលជាច្រើនទៀត នៅតែយល់ថាការងារបញ្ជ្រាបយេនឌ័រ គឺជាបន្ទុករបស់ក្រសួងកិច្ចការនារី ។
- គោលនយោបាយយេនឌ័រតាមក្រសួង ស្ថាប័នពុំសូវមានការត្រួតពិនិត្យ តាមដានវាយតម្លៃ ទៅតាមតម្រូវការបញ្ជ្រាបយេនឌ័រជាក់ស្តែង។
- នៅក្នុងគោលនយោបាយគ្រប់វិស័យ ក៏ដូចជានៅក្នុងគោលនយោបាយ និងកម្មវិធីនានាស្តីពីសមភាពយេនឌ័រ នៅមិនទាន់បានលើកឡើងពីតម្រូវការពិតប្រាកដរបស់ជនដែលងាយរងគ្រោះជាស្ត្រី និងក្មេងស្រីនៅឡើយ[3] ។

[3] មានជាអាទិ៍ៈ ស្ត្រី និងក្មេងស្រីពិការ ស្ត្រីវ័យចំណាស់ ស្ត្រី និងក្មេងស្រីមានផ្ទុកមេរោគអេដស៍ ស្ត្រីមេម៉ាយ និងស្ត្រីជាមេគ្រួសារ ស្ត្រី និងកុមារី ដែលមក ពីក្រុមជាជនជាតិដើមភាគតិច និងជនជាតិភាគតិច ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទនិងក្រុមមនុស្សកែភេទ ស្ត្រីទទួលរងគ្រោះដោយ សារអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងកូនរបស់ពួកគេ ស្ត្រី ដែលធ្លាប់ទទួលរងគ្រោះដោយសារអំពើហិង្សាផ្លូវភេទ និង/ឬការ រៀបការដោយបង្ខំក្នុង អំឡុងរបបខ្មែរក្រហម ស្ត្រី និងក្មេងស្រី ដែលកំពុងរស់នៅតំបន់ដាច់ស្រយាល ស្ត្រីជាប់ពន្ធនាគារ និងស្ត្រី ដែលពាក់ព័ន្ធក្នុងសេវាផ្លូវភេទ និង/ឬស្ត្រី ដែលកំពុងធ្វើការនៅទីកន្លែងកំសាន្តរបស់បុរស។

## អនុសាសន៍សម្រាប់គោលនយោបាយ

- អភិវឌ្ឍសមត្ថភាពរបស់ក្រសួងកិច្ចការនារីលើការវិភាគគោលនយោបាយដែលឆ្លើយតបនឹងយេនឌ័រ ការស្វែងរកការគាំទ្រមតិ និងការសម្របសម្រួល ដើម្បីពង្រឹងលទ្ធភាពក្នុងការបញ្ជ្រាបយេនឌ័រទៅគ្រប់ក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាលនៅគ្រប់កម្រិត។
- ពង្រឹងសមត្ថភាពក្នុងការវិភាគ និងការធ្វើផែនការសម្រាប់បញ្ជ្រាបយេនឌ័រនៅក្នុងក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល រួមទាំងការប្រមូលនិងវិភាគទិន្នន័យរបស់ក្រសួងផែនការ និង ក្រសួងស្ថាប័ននានា ព្រមទាំងពង្រឹងសមត្ថភាពនៃការប្រមូលទិន្នន័យផ្ទៃក្នុងរបស់ក្រសួងកិច្ចការនារី។
- ពង្រឹងទំនាក់ទំនងកាន់តែរឹងមាំបន្ថែមទៀតរវាងនាយកដ្ឋានបច្ចេកទេសក្រសួងកិច្ចការនារីនិងក្រុម ការងារយេនឌ័រតាមក្រសួងស្ថាប័ន (GMAGs) ព្រមទាំងជាមួយក្រុមការងារបច្ចេកទេសចម្រុះផ្សេងៗ (TWGs) ហើយជានាថា ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រតាមក្រសួងស្ថាប័ន (GMAPs) បានកែសម្រួលដោយផ្អែកលើរបកគំហើញ និងអនុសាសន៍របស់ CGA/NRIV ហើយនិងបានដាក់បញ្ចូលយ៉ាងពេញលេញទៅក្នុងផែនការមេ និងវដ្តនៃផែនការថវិការបស់ក្រសួង ស្ថាប័ន ព្រមទាំងពង្រឹងប្រព័ន្ធត្រួតពិនិត្យតាមដាន វាយតម្លៃ និងការធ្វើរបាយការណ៍មកក្រសួងកិច្ចការនារី ។
- ក្រសួងកិច្ចការនារីគួរប្រើប្រាស់បណ្ដាញថ្នាក់ក្រោមជាតិរបស់ខ្លួនឱ្យបានកាន់តែប្រសើរឡើងក្នុងការលើកកម្ពស់គណនេយ្យភាពសង្គមដែលឆ្លើយតបនឹងយេនឌ័រនៅថ្នាក់មូលដ្ឋាន ជាពិសេសតាមរយៈការពង្រឹងទំនាក់ទំនងជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប និងអនុកម្មវិធីទាំងប្រាំមួយនៃផអ៣ ក្នុងក្របខ័ណ្ឌគណនេយ្យភាពសង្គមនិងអភិបាលកិច្ចល្អ (ក្រុមប្រឹក្សាឃុំ សង្កាត់) និងការផ្ដល់សេវា (ការអប់រំ សុខភាព និងសេវាផ្លូវច្បាប់) និងកិច្ចគាំពារសង្គម។
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គួរបន្តអនុវត្តការផ្ដួចផ្ដើមក្នុងការរៀបចំផែនការថវិកាដែលឆ្លើយតបទៅនឹងយេនឌ័រ (GRB) ក្នុងក្របខ័ណ្ឌកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFMRP) និងក្របខ័ណ្ឌ រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់កម្រិត ដូចជា ការដាក់បញ្ចូលប្រយោគយេនឌ័រទៅក្នុងគោលការណ៍ណែនាំសម្រាប់

ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា (BSP) និងថវិកាតាមកម្មវិធីសម្រាប់ក្រសួងស្ថាប័ន និងពន្លឿនការរៀបចំគោលនយោបាយ រៀបចំថវិកាដែលឆ្លើយតបនឹងយេនឌ័រនៅថ្នាក់ក្រោមជាតិ ដើម្បីធានាថា យេនឌ័រត្រូវបានយកចិត្តទុកដាក់ និងដាក់បញ្ចូលក្នុងដំណើរការនៃការរៀបចំថវិកា ជាពិសេសក្នុងសូចនាករគោលដៅប្រចាំឆ្នាំ និងលទ្ធផលចុងក្រោយ។

- ក្រសួងកិច្ចការនារីគួរបញ្ចូលនូវអនុសាសន៍ជាក់លាក់សម្រាប់បញ្ជ្រាបយេនឌ័រទៅក្នុងផែនការយុទ្ធសាស្ត្រគាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ (NSPS) និងឧបករណ៍គាំពារសង្គមនានា ក្នុងដំណើរការកែសម្រួលផែនការនេះ។
- ក្រសួងកិច្ចការនារីគួរប្រើប្រាស់បទពិសោធន៍របស់អង្គការពលកម្មអន្តរជាតិ (ILO) និងគ.ជ.អ.ប ក្នុងការធ្វើសវនកម្មយេនឌ័រសម្រាប់ការវាយតម្លៃការបញ្ជ្រាបយេនឌ័ររបស់ក្រសួងស្ថាប័ននៅតាមវិស័យ និងកម្មវិធីកំណែទម្រង់នានា។
- ធ្វើការសិក្សាស្រាវជ្រាវបន្ថែមទៀត និងចាត់វិធានក្នុងការអភិវឌ្ឍន៍សមត្ថភាព ដើម្បីកែលម្អការយល់ដឹងអំពីស្ត្រីនិងក្មេងស្រី និងដើម្បីបញ្ជ្រាបតម្រូវការរបស់ពួកគេទៅក្នុងកម្មវិធី និងគោលនយោបាយតាមវិស័យ។

## ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចសម្រាប់ស្ត្រី

យុទ្ធសាស្ត្ររបស់ក្រសួងកិច្ចការនារីក្នុងការផ្តល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីរួមមានការជម្រុញឱ្យស្ត្រីបានចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច និងចូលរួមចំណែកសម្រេចគោលដៅប្រទេសជាតិ ដូចជាការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រកបដោយសមធម៌និងមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធដែលជាគន្លឹះ ក្នុងការឈានទៅសម្រេចសមភាពយេនឌ័រនៅកម្ពុជា។ ការផ្តល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីរួមបញ្ចូលការលើកកំពស់ការងារសមរម្យនិងមានប្រាក់កម្រៃ ការអភិវឌ្ឍន៍សហគ្រាសខ្នាតមីក្រូ តូច និងមធ្យម ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសលើស្ត្រី និងការពិនិត្យមើលទីផ្សារការងារនៅកម្ពុជា រួមទាំងបញ្ហាប្រឈមនានាដែលស្ត្រីជួបប្រទះក្នុងការស្វែងរកការការងារសមរម្យ។ ការប្រែប្រួលអាកាសធាតុនិងការអភិវឌ្ឍន៍បៃតង ក៏ជាឧបសគ្គយ៉ាងធំផងដែរសម្រាប់ការផ្តល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចសម្រាប់ស្ត្រី។

## សមិទ្ធផលសំខាន់ៗ

កម្ពុជាទទួលបានសមិទ្ធផលយ៉ាងធំធេង ក្នុងការពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ។ គោលដៅ របស់រាជរដ្ឋាភិបាលកម្ពុជា គឺការបង្កើនការងារ និងកែលម្អលក្ខខ័ណ្ឌការងារ[4] ដែលចូលរួមចំណែកដោយផ្ទាល់លើការផ្តល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី។ សន្ទស្សន៍វិសមភាពយេនឌ័រ ក្នុងឆ្នាំ២០១៣ បានបង្ហាញថាការចូលរួមរបស់ស្ត្រីក្នុងទីផ្សារការងារមាន៧៩,២០%។ នៅក្នុងសន្ទស្សន៍គម្លាតយេនឌ័រសកល ក្នុងឆ្នាំ២០១៣ ទាក់ទងនឹងការចូលរួមក្នុងផ្នែកសេដ្ឋកិច្ច កម្ពុជាទទួលបានចំណាត់ថ្នាក់ខ្ពស់មធ្យមសម្រាប់ការចូលរួមរបស់ស្ត្រីក្នុងកម្លាំងពលកម្ម[5]។ ការរីកលូតលាស់នៃវិស័យពាណិជ្ជកម្ម សេវាកម្ម ផលិតកម្ម កសិកម្ម សណ្ឋាគារ ផ្ទះសំណាក់ និងភោជនីយដ្ឋាន បានផ្តល់ការងារប្រមាណ ៨៩% នៃការងារសរុបរបស់ស្ត្រី[6]។ អត្រានៃភាពក្រីក្រធ្លាក់ចុះពី២៩,៩០% ក្នុងឆ្នាំ២០០៩ មកនៅត្រឹម១៩,៨០% ក្នុងឆ្នាំ២០១១[7]។ លើសពីនេះឱកាសការងារមានចំនួនកាន់តែច្រើនឡើងសម្រាប់ស្ត្រី និងបុរស ចំណែកការងារដែលងាយរងគ្រោះក៏មានការថយចុះ ។

## បញ្ហាប្រឈម

- ការងារមានប្រាក់កម្រៃផ្តល់ឱកាសជាច្រើនសម្រាប់ស្ត្រី ប៉ុន្តែប្រាក់ឈ្នួលនៅមានកម្រិតទាប លក្ខខ័ណ្ឌការងារមិនសូវអំណោយផល គម្លាតរវាងតម្រូវការការងារនិងការផ្គត់ផ្គង់ការងារ និងសមាហរណកម្ម អាស៊ាន។
- ស្ត្រីមានសក្តានុពលជាច្រើនក្នុងការបង្កើតនិងពង្រីកអាជីវកម្មខ្នាតតូច មីក្រូ និងមធ្យម ប៉ុន្តែពួកគេជួបឧបសគ្គជាច្រើនទាក់ទងនឹងលទ្ធភាពទទួលបានធនធាននិងសេវាអភិវឌ្ឍន៍ជីវកម្ម រួមទាំងធនធានហិរញ្ញវត្ថុ។ លើសពីនេះ សហគ្រាសរបស់ស្ត្រីភាគច្រើនស្ថិតក្នុងវិស័យឧស្សាហកម្មដែលមានផលិតភាពទាប។ ដូចគ្នានេះដែរ ស្ត្រីដែលប្រកបមុខរបរកសិកម្មនៅតាមជនបទ មានលទ្ធភាពតិចតួចក្នុងការទទួលបាន

---

4 ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៤-២០១៨

5 World Economic Forum, Global Gender Gap Index 2014, http://www.weforum.org/issues/global-gender-gap

6 អង្កេតប្រជាសាស្ត្រចន្លោះជំរឿនកម្ពុជា ឆ្នាំ២០១៣

7 បន្ទាត់អត្រាភាពក្រីក្រថ្នាក់ជាតិថ្មីនេះ គឺជាការប៉ាន់ប្រមាណដ៏ទាបលើការចំណាយសម្រាប់ជីវភាពរស់នៅ ដោយផ្អែកលើការចំណាយសម្រាប់កាឡូរី ២.២០០ និងការចំណាយតូចៗផ្សេងៗទៀតមិនមែនសម្រាប់អាហារ។ បន្ទាត់ភាពក្រីក្រថ្មីរបស់ប្រទេសកម្ពុជាគឺ ៣.៨៧១រៀលក្នុងមួយថ្ងៃ (សម្រាប់មនុស្សម្នាក់) នៅឆ្នាំ២០០៩ អត្រានេះមានកម្រិតខ្ពស់ជាងនៅទីក្រុងភ្នំពេញ និងតំបន់ជុំវិញទៅក្រុង និងទាបជាងសម្រាប់តំបន់ឆ្ងាយដាច់ស្រយាល (ក្រសួងផែនការ ឆ្នាំ២០១៣)។



និងកម្មសិទ្ធិលើធនធាន ។ លើសពីនេះ ស្ត្រីធ្វើការងារដែលមិនមានប្រាក់កម្រៃ និងការងារថែទាំផ្សេងៗទៀត ធ្វើឱ្យពួកគេមានពេលវេលានៅសល់តិចតួចសម្រាប់ការងាររកប្រាក់ចំណូល។

- ស្ត្រីកាន់តែច្រើនកំពុងធ្វើចំណាកស្រុកស្វែងរកការងារពីជនបទមកទីក្រុង និងទៅក្រៅប្រទេស ដោយសារឱកាសការងារនៅក្នុងប្រទេសមានកាន់តែច្រើន និងវិស័យសហគ្រាសខ្នាតមីក្រូតូចនិងមធ្យម។ ជាទូទៅ ពួកគេជួបហានិភ័យច្រើនជាងបុរស រួមទាំងអំពើហិង្សាលើរាងកាយ។
- ស្ត្រីមកពីក្រុមងាយរងគ្រោះ ជាពិសេសស្ត្រីពិការ[8] និងស្ត្រីវ័យចំណាស់[9] គឺជាស្ត្រីក្រីក្រ ឬមានប្រាក់ចំណូល តិចជាងស្ត្រី និងបុរសដទៃ រួមទាំងតិចជាងបុរសដែលមកពីក្រុមងាយរងគ្រោះដូចគ្នានោះផងដែរ។

▲ **ផុន សៀងខេង (៤១ឆ្នាំ)**ជាអាជីវករលក់ដូរនៅផ្សារថ្មី នាទីក្រុងភ្នំពេញ ។ អ្នកស្រី ខេង ប្រកបរបរលក់គ្រឿងសមុទ្រនេះជិត១៥ឆ្នាំមកហើយ ។

---
[8] អង្កេតប្រជាសាស្ត្រចន្លោះជំរឿន ឆ្នាំ២០១៣
[9] អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា ឆ្នាំ២០១២

- បម្រែបម្រួលអាកាសធាតុបានធ្វើឱ្យកើនឡើងនូវហានិភ័យនៃគ្រោះធម្មជាតិ (ទឹកជំនន់ និងភាពរាំងស្ងួត) និងមានឥទ្ធិពលអវិជ្ជមានលើផលិតផលកសិកម្ម ការអភិវឌ្ឍន៍សហគ្រាសខ្នាតមីក្រូ តូច និងមធ្យម ឱកាសការងារ និងជីវភាពរស់នៅរបស់ស្ត្រី។ ហេតុដូចនេះ ស្ត្រីមានតួនាទីក្នុងការបន្សាំនិងកាត់បន្ថយភាពរងគ្រោះដែលទាក់ទងនឹងបម្រែបម្រួលអាកាសធាតុ (ការអភិវឌ្ឍន៍បៃតង) និងការធ្វើឱ្យបរិស្ថានមាននិរន្តរភាព។

- ការងារមានប្រាក់កម្រៃផ្តល់ឱកាសជាច្រើនសម្រាប់ស្ត្រី ប៉ុន្តែប្រាក់ឈ្នួលនៅមានកម្រិតទាប លក្ខខ័ណ្ឌការងារមិនសូវអំណោយផល គម្លាតរវាងតម្រូវការការងារ និងការផ្គត់ផ្គង់ការងារ និងសមាហរណកម្មអាស៊ាន។

- ស្ត្រីមានសក្តានុពលជាច្រើនក្នុងការបង្កើត និងពង្រីកអាជីវកម្មខ្នាតតូច មីក្រូ និងមធ្យម ប៉ុន្តែពួកគេជួបឧបសគ្គជាច្រើនទាក់ទងនឹងលទ្ធភាពទទួលបានធនធាន និងសេវាអភិវឌ្ឍន៍អាជីវកម្ម រួមទាំងធនធានហិរញ្ញវត្ថុ។ លើសពីនេះ សហគ្រាសរបស់ស្ត្រីភាគច្រើន ស្ថិតក្នុងវិស័យឧស្សាហកម្មដែលមានផលិតភាពទាប។ ស្ត្រីធ្វើការងារដែលមិនមានប្រាក់កម្រៃ និងការងារថៃទាំផ្សេងៗទៀត ធ្វើឱ្យពួកគេមានពេលវេលានៅសល់តិចតួចសម្រាប់ការងាររកប្រាក់ចំណូល។

- ស្ត្រីកាន់តែច្រើនកំពុងចំណាកស្រុកស្វែងរកការងារពីជនបទមកទីក្រុង និងទៅក្រៅប្រទេស។ ជាទូទៅ ពួកគេជួបហានិភ័យច្រើនជាងបុរស រួមទាំងអំពើហិង្សាលើរាងកាយ។

- បម្រែបម្រួលអាកាសធាតុបានធ្វើឱ្យកើនឡើងនូវហានិភ័យនៃគ្រោះធម្មជាតិ (ដូចជាទឹកជំនន់ និងភាពរាំងស្ងួតជាដើម) និងមានឥទ្ធិពលអវិជ្ជមានលើផលិតផលកសិកម្ម ការអភិវឌ្ឍន៍សហគ្រាសខ្នាតមីក្រូ តូច និងមធ្យម និងឱកាសការងារនិងជីវភាពរស់នៅរបស់ស្ត្រី។

## អនុសាសន៍សម្រាប់គោលនយោបាយ

- ពង្រឹងយន្តការលើកកម្ពស់អភិក្រមគ្រប់គ្រងទូទាំងកម្មវិធី ស្តីពីការផ្តល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចសម្រាប់ស្ត្រី រួមទាំងយុទ្ធសាស្ត្រផ្តល់ភាពអង់អាចផ្នែកសេដ្ឋកិច្ច

សម្រាប់ស្ត្រី និងក្របខ័ណ្ឌពន្លឿនគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ឱ្យកាន់តែមានលក្ខណៈជាប្រព័ន្ធ។

- ពង្រឹងកិច្ចសហការរវាងក្រសួងកិច្ចការនារី ជាមួយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងការផ្តល់កម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ដោយផ្តោតជាសំខាន់លើស្ត្រី ដែលមានលក្ខណៈជាប្រព័ន្ធ។

- ពង្រីកសហការជាមួយអ្នកពាក់ព័ន្ធនានានៅក្នុងទីផ្សារការងារ (អង្គការពលកម្មអន្តរជាតិ សមាគមរោងចក្រកាត់ដេរ អង្គការក្រៅរដ្ឋាភិបាល និងវិស័យឯកជន) ក្នុងការស្វែងរកការគាំទ្រមតិ លើការរើសអើងលើស្ត្រីនៅកន្លែងការងារ និងបង្ហាញស្តង់ដារការងារ កិច្ចការពារសង្គម រួមទាំងការកែសម្រួលលច្បាប់ និងបទបញ្ញត្តិនានាដើម្បីលើកកម្ពស់សមភាពយេនឌ័រ។

- ពង្រឹងកិច្ចសហការជាមួយក្រសួងពាក់ព័ន្ធ ក្នុងការលើកកម្ពស់ការបង្កើត និងការប្រតិបត្តិរបស់សមាគមសហគ្រិនស្ត្រី ក្រុមស្ត្រីអ្នកផលិត និងលើកទឹកចិត្តស្ត្រីចូលរួមបណ្តាញអាជីវកម្មនានា ដូចជាវេទិការាជរដ្ឋាភិបាលរវាងវិស័យសាធារណៈ និងវិស័យឯកជន។

- ក្រសួងកិច្ចការនារីគួរបន្ត និងពង្រីកការលើកកម្ពស់ការយល់ដឹងពីសេវាអភិវឌ្ឍន៍អាជីវកម្មសំខាន់ៗ សម្រាប់សហគ្រិនស្ត្រីខ្នាតមីក្រូ តូច និងមធ្យម រួមទាំងសេវាហិរញ្ញវត្ថុ ការអប់រំពីហិរញ្ញវត្ថុ និងព័ត៌មាននិងចំណេះដឹងទាក់ទងនឹងអាជីវកម្ម តាមរយៈភាពជាដៃគូជាមួយស្ថាប័នសាធារណៈ និងឯកជន ដែលផ្តល់សេវាអភិវឌ្ឍន៍អាជីវកម្ម រួមទាំងស្ថាប័នមីក្រូហិរញ្ញវត្ថុ ។

- បន្តគាំទ្រស្ត្រីក្នុងការធ្វើពិពិធកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម និងបង្កើនសកម្មភាពសេដ្ឋកិច្ចដែលមិនទាក់ទងនឹងកសិកម្ម។

- បន្តជំរុញ និងគាំទ្រយន្តការកំណត់អត្តសញ្ញាណជនក្រីក្ររបស់ក្រសួងផែនការឱ្យកាន់តែឆ្លើយតបនឹងយេនឌ័រ។

- គួរផ្តល់សច្ចាប័នលើអនុសញ្ញារបស់អង្គការពលកម្មអន្តរជាតិ ស្តីពីពលករក្នុងស្រុក

និងអនុសញ្ញាស្តីពីការការពារពលករទេសន្តប្រវេសន៍ និងគ្រួសាររបស់គេ។

- គួរលើកទឹកចិត្តដល់និយោជក និងគ្រឹះស្ថានសិក្សានិងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈគោលនយោបាយពន្ធដារ និងច្បាប់ ក្នុងការជ្រើសរើសបុគ្គលិកនិងសិក្សាអំពីស្ត្រីមកពីក្រុមងាយរងគ្រោះ ជាពិសេសស្ត្រីរងគ្រោះពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ ស្ត្រីជនជាតិភាគតិច និងស្ត្រីកាន់សាសនាផ្សេងៗ ស្ត្រីពិការ ស្ត្រីមានផ្ទុកមេរោគអេដស៍/ជម្ងឺអេដស៍ ស្ត្រីស្រឡាញ់ភេទដូចគ្នា និងក្រុមមនុស្សកែភេទ ក៏ដូចជាកូនរបស់ស្ត្រីមេម៉ាយ និងស្ត្រីជាមេគ្រួសារ។
- បង្កើនវិធានការផ្តល់សុវត្ថិភាពជូនស្ត្រីមេម៉ាយនិងស្ត្រីទាំងឡាយនៅពេលពួកគេចូលក្នុងវ័យចាស់ជរា (ការពង្រីកប័ណ្ណក្រីក្រដល់គ្រួសារដែលមានសមាជិកអាយុច្រើនជាង៧០ឆ្នាំ)។
- ប្រើប្រាស់មជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី ក្នុងការធ្វើយុទ្ធនាការទាក់ទងនឹងការប្រែប្រួលអាកាសធាតុ និងអភិវឌ្ឍសមត្ថភាពដល់ស្ត្រី ក្នុងការត្រៀមខ្លួនទប់ទល់នឹងគ្រោះមហន្តរាយនានា ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ។

## សមភាពយេនឌ័រក្នុងវិស័យអប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ

ដើម្បីសម្រេចបាននូវការអប់រំសម្រាប់ទាំងអស់គ្នា ក៏ដូចជាការអភិវឌ្ឍន៍សង្គមកម្ពុជាទាំងមូល រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបាន និងកំពុងធ្វើការបញ្ជ្រាបយេនឌ័រយ៉ាងសស្រាក់សស្រាំទៅក្នុងវិស័យអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ កន្លងមក សមភាពយេនឌ័រត្រូវបានបញ្ជ្រាបទៅក្នុងច្បាប់ គោលនយោបាយ ផែនការ និងកម្មវិធីពាក់ព័ន្ធសំខាន់ៗនានា រួមជាមួយការអប់រំផ្សព្វផ្សាយបង្កើនការយល់ដឹងយ៉ាងទូលំទូលាយអំពីសារៈសំខាន់នៃការចូលរួមដោយស្មើភាពគ្នារបស់ស្ត្រី និងក្មេងស្រី ក្នុងការអប់រំ និងបណ្តុះបណ្តាលនៅគ្រប់កម្រិត។ ជាលទ្ធផល ផ្នត់គំនិតសង្គមដែលរារាំងដល់ការទទួលបានការអប់រំរបស់ស្ត្រីនិងក្មេងស្រី និងគម្លាតយេនឌ័រក្នុងវិស័យអប់រំ ត្រូវបានលុបបំបាត់ជាបណ្តើរៗ ។ ទោះជាយ៉ាងណាក៏ដោយ កម្ពុជាត្រូវខិតខំប្រឹងប្រែងជាបន្តទៀត ជាពិសេសក្នុងការលើកកម្ពស់ការទទួលបានការអប់រំរបស់ស្ត្រីនិងក្មេងស្រីនៅកម្រិតឧត្តមសិក្សា និងការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។



▲ សិស្សពូកែជានារីទាំង៥រូប ដែលប្រឡងជាប់ សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិឆ្នាំ២០១៤។ មានសិស្ស១១នាក់ទទួលបាននិទ្ទេស A ក្នុងនោះ មានសិស្សស្រីចំនួន៥នាក់៖
**អិត ស្រីពៅ** (១៨ឆ្នាំ) មកពីខេត្តកំពង់ចាម
**សម្បត្តិ វិបុលរ័ត្ន** (១៨ឆ្នាំ) មកពីទីក្រុងភ្នំពេញ
**ចាន់ កិត្យាភារ៉ា** (១៧ឆ្នាំ) មកពីខេត្តកំពង់ស្ពឺ
**អ៊ុត សុខផល្លួន** (១៨ឆ្នាំ) មកពីខេត្តសៀមរាប
**យាន សោភា** (១៨ឆ្នាំ) មកពីខេត្តព្រៃវែង

## សមិទ្ធផលសំខាន់ៗ

ចាប់តាំងពីឆ្នាំ២០០៨ យេនឌ័របានបន្តបញ្ជ្រាបក្នុងគោលនយោបាយ កម្មវិធី និងផែនការក្នុង វិស័យអប់រំ យុវជន និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដូចជា ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០០៩-២០១៣ ផែនការគោលស្តីពីការអភិវឌ្ឍន៍កម្មវិធីសិក្សា ឆ្នាំ២០១០-២០១៤ ផែនការអភិវឌ្ឍគ្រូបង្រៀន ឆ្នាំ២០១០-២០១៤ ផែនការគោលសម្រាប់ការអភិវឌ្ឍសមត្ថភាពក្នុងវិស័យអប់រំ ឆ្នាំ២០១១-២០១៥ ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ឆ្នាំ២០១១-២០១៥ គោលនយោបាយជាតិស្តីពីការអភិវឌ្ឍន៍យុវជន ឆ្នាំ២០១១ គោលនយោបាយស្តីពីធនធានមនុស្សក្នុងវិស័យអប់រំ ឆ្នាំ២០១២ គោលនយោបាយស្តីពីសាលាកុមារមេត្រីសម្រាប់អប់រំមូលដ្ឋាន ឆ្នាំ២០១២ គោលនយោបាយស្តីពីគ្រូបង្រៀន ឆ្នាំ២០១៣ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឆ្នាំ២០១៤-២០១៨ និងយុទ្ធសាស្ត្រ

សមធម៌យេនឌ័រ ក្នុងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឆ្នាំ២០១៤ ជាដើម។

ច្បាប់ គោលនយោបាយ និងផែនការយុទ្ធសាស្ត្រទាំងនេះ បាននិងកំពុងរួមចំណែកក្នុងការលើកកម្ពស់សមភាពយេនឌ័រក្នុងវិស័យអប់រំ និងបណ្តុះបណ្តាល តាមរយៈការផ្តល់បរិយាកាសល្អផ្នែករូបវន្ត ការបង្កើនឱកាសក្នុងការទទួលបាននូវការអប់រំ និងបណ្តុះបណ្តាល ការកែប្រែឥរិយាបថសង្គមដែលរើសអើងលើនារី និងការផ្តល់បរិយាកាសអំណោយផលដល់ការចូលរួមរបស់ស្ត្រីនៅគ្រប់ផ្នែក និងគ្រប់កម្រិត។ នៅកម្រិតមត្តេយ្យសិក្សា ការចូលរៀនរបស់កុមារតូចទាំងពីរភេទមានការកើនឡើងជាបន្តបន្ទាប់ ដែលបានរួមចំណែកក្នុងការបង្កើនភាពវៃឆ្លាត និងទំនុកចិត្តរបស់កុមារនៅពេលចូលរៀននៅបឋមសិក្សា[10]។ នៅបឋមសិក្សា និងមធ្យមសិក្សា ការចុះឈ្មោះចូលរៀនរបស់សិស្សស្រីមានចំនួនប្រហាក់ប្រហែលគ្នានឹងសិស្សប្រុស[11]។ ក្នុងឆ្នាំ២០១២ កុមារីបានចុះឈ្មោះចូលរៀនច្រើនជាងកុមារា និងមចំនួនសរុបច្រើនជាងកុមារានៅកម្រិតមធ្យមសិក្សាបឋមភូមិ[12] ។នៅឧត្តមសិក្សា សមាមាត្រនិស្សិតស្រីកំពុងមានការកើនឡើងជាបណ្តើរៗ ពី៣៣% ក្នុងឆ្នាំ២០០៨ ដល់៣៧,៦% ក្នុងឆ្នាំ២០១១[13]។ ចំណែកឯការចូលរួមរបស់ស្ត្រីនៅក្នុងការអប់រំការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ក៏មានការកើនឡើងគួរឱ្យកត់សម្គាល់ផងដែរ ។

កម្ពុជាមានពិន្ទុខ្ពស់ធៀបនឹងប្រទេសផ្សេងៗនៅក្នុងសន្ទស្សន៍គម្លាតយេនឌ័រសកល [14]

## បញ្ហាប្រឈម

- ផ្នត់គំនិតសង្គមដែលផ្តល់តម្លៃដល់ការអប់រំ និងបណ្តុះបណ្តាលសម្រាប់ក្មេងប្រុសជាងក្មេងស្រី អនក្ខរភាពរបស់មាតាបិតា អំពើហិង្សាក្នុងគ្រួសារ ការរៀបអាពាហ៍ពិពាហ៍របស់ក្មេងស្រីដែលមិនទាន់គ្រប់អាយុ និងកត្តាជីវភាពគ្រួសារនៅតែបន្តកើតមានដែលនាំឱ្យប៉ះពាល់ជាអវិជ្ជមានដល់ការសិក្សារបស់កូនស្រី ។

- កិច្ចគាំពារដល់កុមារនៅមានកម្រិត ជាពិសេសសម្រាប់កុមារី ទាក់ទងនឹងការធ្វើដំណើរទៅមក ដោយសុវត្ថិភាព និងសុខភាពអនាម័យ ។

---

[10] UIS online database UNESCO Institute for Statistics. Available online at: *data.uis.unesco.org/*

[11] ក្រសួងអប់រំ យុវជន និងកីឡា ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ ឆ្នាំ (២០០៨, ២០០៩, ២០១០, ២០១១)

[12] ក្រសួងអប់រំ យុវជន និងកីឡា ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ ឆ្នាំ (២០១២)

[13] ក្រសួងអប់រំ យុវជន និងកីឡា ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ ឆ្នាំ (២០០៨, ២០០៩, ២០១០, ២០១១)

[14] World Economic Forum, Global Gender Gap Index 2014, http://www.weforum.org/issues/global-gender-gap

- ការចូលរួមរបស់សហគមន៍ និងមាតាបិតាក្នុងសកម្មភាពរបស់សាលា ក៏ដូចជាការសិក្សារបស់សិស្សនៅមានកម្រិត។
- ការអនុវត្តគោលនយោបាយ និងផែនការ នៅមានកម្រិតនៅឡើយនៅស្ទើរគ្រប់កម្រិតសិក្សា រួមទាំងសមត្ថភាពធនធានមនុស្ស និងសមត្ថភាពស្ថាប័ន ក្នុងការអនុវត្តន៍ការបញ្រ្ជាបយេនឌ័រនៅថ្នាក់ក្រោមជាតិ នៅមានកម្រិតនៅឡើយ។
- កំណើនឧស្សាហកម្ម និងសមាហរណកម្មសេដ្ឋកិច្ចអាស៊ានក្នុងឆ្នាំ២០១៥ ទាមទារជំនាញនានាដែលត្រូវស្រូបយកក្មេងស្រី និងក្មេងប្រុសចូលក្នុងទីផ្សារការងារ ស្របពេលជាមួយគ្នានៃការកើនឡើងនូវសម្ភារនិយមក្នុងសង្គម។
- ការទទួលបានការអប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈរបស់ក្មេងស្រី និងស្ត្រីពិការនៅតែជាកត្តាចម្បងដែលត្រូវយកចិត្តទុកដាក់បន្ថែមទៀត។
- កូនរបស់ស្ត្រីដែលរងគ្រោះពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ[15] កុមារីពិការ[16] ស្ត្រីស្រឡាញ់ភេទដូចគ្នានិងក្រុមមនុស្សកែភេទ[17] មានអត្រាអវត្តមាន និងបោះបង់ចោលការសិក្សាច្រើនជាងគេ ដោយសារតែស្ថានភាពផ្ទាល់ខ្លួន និងស្ថានភាពគ្រួសាររបស់ពួកគេ ឬដោយសារមានការរើសអើងពីមិត្តរួមថ្នាក់។

## អនុសាសន៍សម្រាប់គោលនយោបាយ

ខាងក្រោមនេះជាអនុសាសន៍ទូទៅមួយចំនួន ដើម្បីបន្តលើកកម្ពស់សមភាពយេនឌ័រក្នុងវិស័យអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ៖

- គួរពិនិត្យឡើងវិញ និងកែទម្រង់នូវក្របខ័ណ្ឌច្បាប់ និងគោលនយោបាយនានាក្នុងវិស័យអប់រំ ដើម្បីបន្ថែម និងពន្លឿនសកម្មភាពបញ្រ្ជាបយេនឌ័រក្នុងវិស័យអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។
- គួរពង្រីកបន្ថែមទៀតនូវការអភិវឌ្ឍន៍សមត្ថភាពធនធានមនុស្ស និងស្ថាប័ន ដើម្បីអនុវត្ត និងពិនិត្យតាមដាននូវការអនុវត្តគោលនយោបាយ និងផែនការនានាសម្រាប់ការបញ្រ្ជាបយេនឌ័រ ។

---

15 Ministry of Women's Affairs (2009) Violence Against Women, Follow Up Survey. Phnom Penh.

16 UNESCAP (2012), Disability, Livelihood and Poverty in Asia and the Pacific, Bangkok, Thailand; and Handicap International (2009), Briefing Paper: Disability Facts in Cambodia, Phnom Penh, Cambodia.

17 UNESCO (2012) Review of Homophobic Bullying in Educational Institutions, Paris, France; from Cambodian Center for Human Rights (2012), Rainbow Khmer: From Prejudice to Pride, Phnom Penh, Cambodia.

- គួរពង្រឹងការរៀបចំកម្មវិធីជាក់លាក់ផ្នែកយេនឌ័រ និងកែលម្អគុណភាពនៃការអប់រំ និងការបណ្តុះបណ្តាលសម្រាប់ស្ត្រី និងក្មេងស្រី ជាពិសេសស្ត្រីជនជាតិដើមភាគតិច និងស្ត្រីពិការ។
- បង្កើនការស្វែងរកការគាំទ្រមតិ និងកិច្ចប្រឹងប្រែងលើកកម្ពស់ការយល់ដឹង ដើម្បីលុបបំបាត់ផ្នត់គំនិតសង្គមដែលរើសអើងលើស្ត្រី និងក្មេងស្រី ។
- គួរបន្តបញ្ចូលខ្លឹមសារអប់រំកាន់តែជាក់លាក់ ស្តីពី «ភាពខុសគ្នានៃទំនៀមទម្លាប់និងការរស់នៅរបស់មនុស្សក្នុងសង្គមបច្ចុប្បន្ន និងឆ្លុះបញ្ចាំងនូវតថភាពជាក់ស្តែងនៃបញ្ហារបស់ស្ត្រីនិងកុមារីដែលស្ថិតក្នុងក្រុមងាយរងគ្រោះ និងដើម្បីបណ្តុះគំនិតក្នុងការលុបបំបាត់ការរើសអើង និងលើកកម្ពស់សិទ្ធិរបស់ពួកគេ» ទៅក្នុងកម្មវិធីសិក្សារបស់សាលារៀន។

## យេនឌ័រ និងសុខភាព

បទដ្ឋាន តួនាទី និងទំនាក់ទំនងយេនឌ័រ មានផលប៉ះពាល់ដល់លទ្ធភាពទទួលបានសេវាសុខភាពរបស់ស្ត្រី បុរស ក្មេងស្រី និងក្មេងប្រុស។ ស្ត្រី និងបុរស ក្មេងស្រី និងក្មេងប្រុស មានលទ្ធភាពនិងតម្រូវការខុសគ្នាក្នុងការការពារនិងលើកកម្ពស់សុខភាពរបស់ពួកគេ ដែលតម្រូវមានការទទួលស្គាល់ជាផ្លូវការនៅក្នុងគោលនយោបាយ និងសេចក្តីណែនាំនានា និងការរៀបចំគម្រោងថវិកាដើម្បីធ្វើផែនការអន្តរាគមន៍ផ្នែកសុខភាពបានសមស្រប។

រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំមានគោលនយោបាយជាតិស្តីពីសមធម៌យេនឌ័រ ដើម្បីដាក់បញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា។

ការបញ្ចូលអភិក្រមយេនឌ័រទៅក្នុងប្រព័ន្ធសុខភាពសាធារណៈ តម្រូវមានការប្តេជ្ញាចិត្តខ្ពស់ពីសំណាក់ថ្នាក់ដឹកនាំជាន់ខ្ពស់ ដើម្បីធានាថា បញ្ហានិងបទពិសោធន៍ទាក់ទងនឹងសុខភាពរបស់ស្ត្រី និងបុរស គឺជាផ្នែកមួយដ៏សំខាន់ដែលត្រូវពិចារណានៅក្នុងការតាក់តែង អនុវត្ត ត្រួតពិនិត្យ និងវាយតម្លៃទៅលើយុទ្ធសាស្ត្រនានាក្នុងវិស័យសុខាភិបាល[18]។

[18] អង្គការសុខភាពពិភពលោក ឆ្នាំ២០១១៖ *Human Rights and Gender Equality in Health Sector Strategies: How to Assess PolicyCoherence.* (With SIDA and United Nations Human Rights). Geneva, Switzerland.



▲ **វេជ្ជបណ្ឌិត កែវ ម៉ៅ (៤៩ឆ្នាំ)** រៀនវិជ្ជាពេទ្យនៅប្រទេសកម្ពុជា និងបម្រើការជាវេជ្ជបណ្ឌិតជាង២០ឆ្នាំមកហើយ ។ គាត់ជាគ្រូពេទ្យផ្នែកថែទាំស្ត្រីមានផ្ទៃពោះ ដោយសារគាត់ចង់ថែទាំស្ត្រីមានផ្ទៃពោះឱ្យមានសុខភាពកាន់តែប្រសើរឡើង ។

**នុត វ៉ាន់ធឿន (៣២ឆ្នាំ)** ជាអ្នកពិគ្រោះជំងឺនៅក្លីនិកដែលវេជ្ជបណ្ឌិត កែវ ម៉ៅធ្វើការ ។ វ៉ាន់ធឿនមានកូន២នាក់ និងកំពុងពរពោះកូនទី៣។ គាត់មកក្លីនិកថ្ងៃនេះ ដើម្បីពិនិត្រផ្ទៃពោះ ។

## សមិទ្ធផលសំខាន់ៗ

### *ការថយចុះនៃអត្រាមរណភាពមាតា*

អត្រាមរណភាពមាតាមានការថយចុះច្រើនជាងពាក់កណ្តាល ពី៤៧២ ក្នុងចំណោម១០០.០០០កំណើតរស់ ក្នុងឆ្នាំ២០០៥ មកត្រឹម២០៦ក្នុងចំណោម១០០.០០០កំណើតរស់ ក្នុងឆ្នាំ២០១០[19]។ ជាមួយគ្នានេះដែរ ការទទួលបានការថែទាំសុខភាពមាតាក៏មានភាពប្រសើរឡើងជាលំដាប់ក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ[20]។ និន្នាការវិជ្ជមានទាំងនេះបានបន្តដោយសារមានអន្តរាគមន៍ជាច្រើនរបស់ក្រសួងសុខាភិបាល ក្រសួងកិច្ចការនារី ព្រមទាំងស្ថាប័ន និងដៃគូពាក់ព័ន្ធ ក្នុងការពង្រីកការផ្តល់សេវាថែទាំសុខភាពនៅតាម

[19] អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ២០១០ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

[20] Wang, Wenjuan (2013) *Assessing Trends in Inequalities in Maternal and Child Health and Health Care in Cambodia.* DHS Further Analysis Reports No. 86. Calverton, Maryland, USA: ICF International.

មណ្ឌលសុខភាព កម្មវិធីអប់រំ និងផ្សព្វផ្សាយដោយភ្នាក់ងារអប់រំសុខភាពភូមិ។

### *ស្ថានភាពអាហារូបត្ថម្ភរបស់ស្ត្រី និងកុមារ*

អត្រាជំងឺក្រេះក្រិនចំពោះកុមារមានការថយចុះពី៥០ %ក្នុងឆ្នាំ២០០០ មកត្រឹម៤០% ក្នុងឆ្នាំ២០១០។ អត្រាស្គមស្គាំងថយចុះពី ១៧% ក្នុងឆ្នាំ២០០០ មក១១ %ក្នុងឆ្នាំ២០១០[21]។

### *សុខភាព និងអំពើហិង្សាទាក់ទងនឹងយេនឌ័រ*

ស្របតាមផែនការសកម្មភាពជាតិដើម្បីទប់ស្កាត់អំពើហិង្សាលើស្ត្រីលើកទី២ ឆ្នាំ២០១៤-២០១៨ ក្រសួងសុខាភិបាល ដោយសហការជាមួយក្រសួងកិច្ចការនារី និងស្ថាប័នពាក់ព័ន្ធ បាននិងកំពុងរៀបចំគោលការណ៍ណែនាំស្តីពីការព្យាបាលគ្លីនិកដល់ស្ត្រី និងកុមារដែលរងគ្រោះដោយអំពើហិង្សា។

### *សុខភាពយុវវ័យ*

ព័ត៌មាន ស្តីពីសុខភាពបន្តពូជ និងសុខភាពផ្លូវភេទ គឺមានសារសំខាន់សម្រាប់ផ្តល់ដល់យុវវ័យឱ្យយល់ដឹងពីសិទ្ធិបន្តពូជ និងសិទ្ធិផ្លូវភេទរបស់ពួកគេ។ ក្នុងឆ្នាំ២០១៣ រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តនូវកម្មវិធីសិក្សាដ៏ទូលំទូលាយមួយសម្រាប់យុវវ័យនៅថ្នាក់បឋមនិងមធ្យមសិក្សា និងយុវវ័យនៅក្រៅសាលា ដោយរួមបញ្ចូលនូវព័ត៌មាន ស្តីពីសិទ្ធិសុខភាពបន្តពូជ និងសុខភាពផ្លូវភេទភ្ជាប់នឹងអាយុយេនឌ័រ អំពើហិង្សាទាក់ទងនឹងយេនឌ័រ គ្រឿងញៀន ការអប់រំបំណិនជីវិត និងមេរោគអេដស៍ ជំងឺអេដស៍។

## បញ្ហាប្រឈម

- បញ្ហាមួយចំនួននៅតែកើតមាន ដូចជាការខ្វះខាតអ្នកផ្តល់សេវាដែលមានជំនាញនៅតំបន់ដាច់ស្រយាល ការខ្វះខាតឱសថនិងសម្ភារៈបរិក្ខារទំនើបនៅក្នុងមូលដ្ឋានសុខាភិបាល និងកម្រិតនៃការយល់ដឹងនិងឥរិយាបថរបស់ស្ត្រីក្នុងការស្វែងរកព័ត៌មាននិងសេវាព្យាបាល មានកម្រិតទាបដោយសារតែកត្តាសង្គម វប្បធម៌ និងសេដ្ឋកិច្ច។ ភាពក្រីក្រ និងអំពើហិង្សាក្នុងគ្រួសារ បានជំរុញឱ្យស្ត្រីនិងក្មេងស្រីប្រឈមនឹងការលំបាកយ៉ាងខ្លាំងចំពោះបញ្ហាសុខភាព។

[21] អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ២០១០ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

- ទោះបីជាអត្រាមរណភាពមាតាមានការថយចុះគួរកត់សម្គាល់ក៏ដោយ ប៉ុន្តែនៅមានវិសមភាពនៅឡើយទាក់ទងនឹងការទទួលបានសេវាសុខភាព ហើយអត្រាមរណភាពមាតានៅតែមានកម្រិតខ្ពស់ធៀបនឹងប្រទេសនានាក្នុងតំបន់។ អត្រាប្រេវ៉ាឡង់នៃប្រើប្រាស់មធ្យោបាយពន្យាកំណើតមានការកើនឡើងជាបន្តបន្ទាប់ក៏ដោយ ប៉ុន្តែពុំទាន់គ្រប់តាមតម្រូវការនៅឡើយ (នៅខ្វះ១៧%)[22]។ ជំងឺមួយចំនួនទៀតដែលកំពុងមានការកើនឡើងគួរបារម្ភ ហើយស្ត្រីជួបប្រទះនូវការខ្វះខាតក្នុងការទទួលបានសេវាពិនិត្យសុខភាព មានដូចជាជម្ងឺមហារីកសួ្ឌន និងសុដន់ជាដើម។

- ផលប៉ះពាល់អវិជ្ជមាននៃស្ថានភាពអាហារូបត្ថម្ភ អាចជាប់ទាក់ទងនឹងលទ្ធភាពទទួលបានទឹកស្អាត និងបង្គន់អនាម័យនៅមានកម្រិត។

- អត្រាប្រេវ៉ាឡង់នៃភាពពិការភ្នែក គឺមានកម្រិតខ្ពស់ក្នុងចំណោមស្ត្រី អាយុលើសពី៥០ឆ្នាំ គឺ ៣.៤% ធៀបទៅនឹង ២% ក្នុងចំណោមបុរសនៅក្នុងក្រុមអាយុដូចគ្នា[23]។ មិនមានការពន្យល់ពីភាពខុសគ្នានៃអត្រាប្រេវ៉ាឡង់នៃភាពពិការភ្នែកក្នុងចំណោមបុរស និងស្ត្រីនៅឡើយ ដែលចំណុចនេះទាមទារឱ្យមានការសិក្សាស្រាវជ្រាវជាបន្តទៀត និងពង្រីកការផ្តល់សេវាគាំទ្រឱ្យបានទូលំទូលាយផងដែរ ។

- ឧបសគ្គមួយដែលនៅតែបន្តកើតមានក្នុងប្រទេសជាច្រើន ក៏ដូចជានៅកម្ពុជា គឺភាពរុញរាក្នុងការនិយាយដោយបើកចំហអំពីរឿងរ៉ាវផ្លូវភេទ ជាពិសេសរវាងមាតា និងយុវវ័យ។

- ស្ត្រីនិងកុមារីមួយចំនួនដែលមកពីក្រុមងាយរងគ្រោះមានតម្រូវការសេវាសុខាភិបាល និងសេវាសុខភាពផ្លូវចិត្តច្រើនជាងគេ បើប្រៀបធៀបទៅនឹងស្ត្រីដទៃទៀត (ឧ. ស្ត្រីនិងកុមារីពិការ[24] ស្ត្រីនិងកុមារីដែលមានផ្ទុកមេរោគអេដស៍/ជម្ងឺអេដស៍ ស្ត្រីវ័យចំណាស់[25] ស្ត្រីស្រឡាញ់ភេទដូចគ្នា ក្រុមនុស្សកែភេទ[26] ស្ត្រី

[22] អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ២០១០ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

[23] Seiha, D. and Limburg, H. (2009) Report of the Rapid Assessment for Avoidable Blindness in Cambodia - 2007. National Program for Eye Health, Phnom Penh.

[24] WHO (2012), from GIZ-Social Health Protection Project, Feb 2013, Phnom Penh, Cambodia.

[25] GIZ Cambodia (Feb 2013), *Update on Vulnerable Groups-GIZ Social Health Protection Project*, Phnom Penh, Cambodia

[26] Cambodian Center for Human Rights (2012), *Rainbow Khmer: From Prejudice to Pride*, Phnom Penh, Cambodia

រងគ្រោះពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ រួមទាំងកូនរបស់ពួកគេ[27] ស្ត្រីរងគ្រោះពីអំពើហិង្សាផ្លូវភេទ ស្ត្រីដែលត្រូវបានបង្ខំឱ្យរៀបការនៅក្នុងរបបខ្មែរក្រហម[28] ស្ត្រីប្រកបរបរផ្លូវភេទ និងស្ត្រីធ្វើការនៅក្នុងកន្លែងកំសាន្តសប្បាយរបស់បុរស[29])។

## អនុសាសន៍សម្រាប់គោលនយោបាយ

- គួរពិនិត្យឡើងវិញ និងកែសម្រួលនូវគោលនយោបាយជាតិ ផែនការយុទ្ធសាស្ត្រសុខាភិបាល គោលការណ៍ណែនាំនានាដែលពុំទាន់ឆ្លើយតបនឹងយេនឌ័រ ឱ្យមានការគិតគូរដល់បញ្ហាយេនឌ័រពេញលេញ ដោយផ្អែកលើការកែលំអគុណភាពសុខាភិបាលសម្រាប់ស្ត្រី ក្មេងស្រី បុរស និងក្មេងប្រុស។
- បន្តបង្កើនការយកចិត្តទុកដាក់ និងផ្តល់មូលនិធិសម្រាប់អនុវត្ត ផែនទីចង្អុលផ្លូវសម្រាប់ពន្លឿនការកាត់បន្ថយអត្រាស្លាប់របស់ម្តាយនិងទារកឆ្នាំ២០១០-២០១៥។
- ពង្រីក និងពង្រឹងបន្ថែមទៀត នូវកម្មវិធីការបណ្តុះបណ្តាល ស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភសម្រាប់បុគ្គលិកសុខាភិបាលជំនាញ និងមន្ត្រីមកពីស្ថាប័នពាក់ព័ន្ធ ដើម្បីតាមដាននិងវាយតម្លៃស្ថានភាពអាហារូបត្ថម្ភនៅកម្រិតសហគមន៍ ជាពិសេសសម្រាប់ស្ត្រី និងកុមារ។
- បង្កើនការយកចិត្តទុកដាក់ និងដោះស្រាយបញ្ហាកង្វះទឹកស្អាត និងអនាម័យ ដើម្បីចូលរួមកាត់បន្ថយគម្លាតរវាងតំបន់ជនបទ និងទីក្រុង។
- បង្កើនប្រសិទ្ធភាព នៃការអនុវត្តគោលការណ៍ណែនាំជាតិ ស្តីពីការព្យាបាលគ្លីនិកដល់ស្ត្រី និងកុមារដែលរងគ្រោះដោយអំពើហិង្សា ។
- ជំរុញ និងលើកទឹកចិត្តដល់បុរសឱ្យចូលរួមក្នុងសេវាសុខភាពបន្តពូជ សុខភាពផ្លូវភេទ ការរៀបចំផែនការគ្រួសារ និងរួមចំណែកលុបបំបាត់អំពើហិង្សាក្នុងគ្រួសារ។

---

27 World Health Organization (2013) *Intimate Partner and Sexual Violence Against Women*. Retrieved December 27, 2013 from Media Centre: http://www.who.int/mediacentre/factsheets/fs239/en/

28 Nakagawa, K. (2008) *Gender-based violence during the Khmer Rouge Regime: Stories of survivors from the Democratic Kampuchea (1975-1979)*. Phnom Penh: Cambodian Defenders Project; Natale, K. (2011) *I Could Feel My Soul Flying away from My Body: A Study of Gender-Based Violence during Democratic Kampuchea in Battambang and Svay Rieng Provinces*. Phnom Penh: Cambodian Defenders Project; Braaf, R. (2014) *Sexual Violence against Ethnic Minorities during the Khmer Rouge Regime*. Phnom Penh: Cambodian Defenders Project

29 National Center for HIV/AIDS, Dermatology and STD of the Ministry of Health (2013), *Behavioural Sentinel Surveillance 2013*, Phnom Penh, Cambodia,

- អភិវឌ្ឍសមត្ថភាពសមត្ថភាពមន្ត្រីក្រសួងកិច្ចការនារីតាមរយៈការផ្ទេរចំណេះដឹងពីទីប្រឹក្សាបច្ចេកទេស ដល់មន្ត្រីពាក់ព័ន្ធរបស់ក្រសួងក្នុងការត្រួតពិនិត្យ តាមដាន និងវាយតម្លៃ កម្មវិធី និងការវិភាគយេនឌ័រក្នុងវិស័យសុខាភិបាល។

- ពង្រឹង និងពង្រីកការអនុវត្តន៍កម្មវិធីផ្សារភ្ជាប់ទំនាក់ទំនងរវាងមាតា និងយុវវ័យ ស្តីពីសុខភាពបន្តពូជ និងសុខភាពផ្លូវភេទ សម្រាប់ជួយមាតាបិតា ឱ្យមានភាពជឿជាក់ និងមានទំនុកចិត្ត ក្នុងការនិយាយដោយបើកចំហពីបញ្ហាយេនឌ័រទាក់ទងនឹងរឿងរ៉ាវផ្លូវភេទជាមួយនឹងបុត្រា បុត្រីរបស់ខ្លួន។

- ពង្រឹង និងពង្រីកការផ្តល់ព័ត៌មានសេវាមេត្រីសុខភាពសម្រាប់យុវវ័យ (Youth Friendly Service) នៅមូលដ្ឋានសុខាភិបាល ក្នុងតំបន់ទីប្រជុំជន និងជនបទ។

- គួរធ្វើការកែលំអ និងលើកកម្ពស់លទ្ធភាពទទួលបាននូវសេវាសុខភាពបន្តពូជ និងសុខភាពផ្លូវភេទ ក៏ដូចជាសេវាផ្លូវចិត្ត និងសេវាចិត្តសាស្ត្រ សម្រាប់ស្ត្រី និងកុមារីពិការ ស្ត្រីវ័យចំណាស់ ស្ត្រីរួមភេទដូចគ្នា ក្រុមមនុស្សប្តូរភេទ ស្ត្រីរងគ្រោះពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងកូនរបស់ពួកគេ ស្ត្រីរងគ្រោះពីអំពើហិង្សាផ្លូវភេទ និង/ឬ ស្ត្រីដែលត្រូវបានបង្ខំឱ្យរៀបការនៅក្នុងរបបខ្មែរក្រហម ស្ត្រី និងកុមារីដែលមានផ្ទុកមេរោគអេដស៍/ជម្ងឺអេដស៍ ស្ត្រីជាប់ពន្ធនាគារ និងស្ត្រីពេស្យា និង/ឬ ស្ត្រីដែលធ្វើការនៅកន្លែងកំសាន្តសប្បាយរបស់បុរស។

## យេនឌ័រ និងមេរោគអេដស៍

កម្ពុជាមានអត្រាផ្ទុកមេរោគអេដស៍ខ្ពស់លំដាប់លេខ២នៅក្នុងតំបន់អាស៊ី[30]។ ទោះបីជាការឆ្លងមេរោគអេដស៍មានការថយចុះគួរឱ្យកត់សម្គាល់នៅក្នុងប្រទេស ហើយការរាលដាលលែងមានលក្ខណៈទូលំទូលាយក៏ដោយ ក៏អត្រាប្រេវ៉ាឡង់ខ្ពស់នៅតែបន្តក្នុងចំណោមក្រុមដែលងាយរងគ្រោះខ្ពស់បំផុត ។

ការឆ្លើយតបទៅនឹងមេរោគអេដស៍នៅកម្ពុជា គឺមានលក្ខណៈពហុវិស័យ ដែលដឹកនាំដោយរាជរដ្ឋាភិបាល និងមានការរួមចំណែកពីស្ថាប័ន និងដៃគូពាក់ព័ន្ធជាច្រើន។

30 UNAIDS (2013). Global Report: UNAIDS report on the global AIDS epidemic.

## សមិទ្ធផលសំខាន់ៗ

អត្រាផ្ទុកមេរោគអេដស៍ក្នុងចំណោមបុរស និងស្ត្រីអាយុពី១៥ ទៅ ៤៩ឆ្នាំ បានថយចុះគួរឱ្យកត់សំគាល់ពី ១,៧០% ក្នុងឆ្នាំ១៩៩៨ មកនៅត្រឹមប្រមាណ ០,៧% ក្នុងឆ្នាំ២០១៤[31] ។ ដោយសារមានការថយចុះនូវការឆ្លងថ្មី តាមរយៈកិច្ចខិតខំប្រឹងប្រែងក្នុងការបង្ការដែលមានគោលដៅច្បាស់លាស់ជាពិសេសក្នុងចំណោមក្រុមដែលប្រឈមមុខនឹងគ្រោះថ្នាក់ខ្ពស់ក្នុងការឆ្លងមេរោគអេដស៍ ការកើនឡើងនូវអត្រាអ្នកធ្វើតេស្តឈាមរកមេរោគអេដស៍ ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ និងភាពកាន់តែប្រសើរឡើងក្នុងការផ្តល់សេវាព័ត៌មាន និងទំនាក់ទំនងផ្សេងៗរបស់ក្រសួង ស្ថាប័ន និងដៃគូពាក់ព័ន្ធ។

កម្ពុជាសម្រេចបាននូវគោលដៅទាក់ទងនឹងលទ្ធភាពទទួលបានសេវាជាសកលសម្រាប់ព្យាបាលស្ត្រីបុរសក្មេងស្រីនិងក្មេងប្រុសក្នុងអត្រាមួយខ្ពស់គឺរហូតដល់ទៅ៨៩,៥% នៃក្រុមប្រជាជនដែលមានតម្រូវការ[32]។ ជាលទ្ធផលដែលកើតចេញពីសមិទ្ធផលនេះ ចំនួនប៉ាន់ស្មានអ្នកស្លាប់ដោយសារជំងឺអេដស៍ និងការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ក៏មានការថយចុះគួរឱ្យកត់សំគាល់នៅក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ។

ដោយមានការចូលរួមពីក្រសួង និងស្ថាប័នពាក់ព័ន្ធ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយនិងពហុវិស័យឆ្លើយតបការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ លើកទី៣ ឆ្នាំ២០១១-២០១៥ រួមទាំងកម្មវិធីបណ្តុះបណ្តាល និងគោលការណ៍ណែនាំ ស្តីពីការបញ្ជ្រាបយេនឌ័រទៅក្នុងការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍។ ក្រសួងកិច្ចការនារី ក៏បានរៀបចំឱ្យមានផែនការយុទ្ធសាស្ត្រ ស្តីពីស្ត្រីក្មេងស្រី និងមេរោគអេដស៍ជំងឺអេដស៍ ឆ្នាំ២០០៨-២០១២ និងកម្មវិធីបណ្តុះបណ្តាល ស្តីពីការបញ្ជ្រាបកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍ទៅក្នុងដំណើរការលើកកម្ពស់សមភាពយេនឌ័រ។

## បញ្ហាប្រឈម

- ការរួមភេទរវាងមនុស្សដែលមានភេទដូចគ្នាគឺជាបែបផែនចម្បងនៃការចម្លងមេរោគអេដស៍ ។

[31] National Centre for HIV/AIDS, Dermatology and STIs, (2011). HIV Estimates and Projections of HIV/AIDS in Cambodia 2011-2015: Report of a Census Workshop. Phnom Penh: Ministry of Health Surveillance Unit, 2011.

[32] National AIDS Authority, (2012a). Cambodia Country Progress Report 2012: Monitoring the Progress towards the Implementation of the Declaration of Commitment on HIV and AIDS. Phnom Penh.

- ការឆ្លងមេរោគអេដស៍មកលើស្ត្រី អាចបណ្តាលមកពីកត្តាជីវសាស្ត្ររបស់ស្ត្រីដែលងាយទទួលការឆ្លង និងដោយសារភាពទន់ខ្សោយរបស់ពួកគេ ព្រមទាំងបរិបទវប្បធម៌ ផ្នត់គំនិតសង្គម និងកង្វះសិទ្ធិអំណាចក្នុងការចរចាពីសុវត្ថិភាពផ្លូវភេទ ឬការប្រើប្រាស់ស្រោមអនាម័យ។ ស្ត្រី និងក្មេងស្រីមួយចំនួនទទួលរងគ្រោះខ្លាំងនូវអំពើហិង្សាផ្លូវកាយ ផ្លូវភេទ និងការរំលោភសេពសន្ថវៈ ហើយក៏អាចជាហេតុនាំឱ្យឆ្លងមេរោគអេដស៍ ។

- កង្វះថវិកា ការភ័យខ្លាចអ្នកដទៃដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍ និងឥរិយាបទអវិជ្ជមានក្នុងចំណោមអ្នកផ្តល់សេវាមួយចំនួនដែលគ្មានឯកទេសខាងជំងឺអេដស៍ បានបង្កជាឧបសគ្គដល់ស្ត្រីដែលផ្ទុកមេរោគអេដស៍ ក្នុងការទទួលបានសេវា និងព័ត៌មានត្រឹមត្រូវអំពីផែនការគ្រួសារ និងការថែទាំទារក ។

- ក្រុមគោលដៅមួយចំនួនងាយនឹងរងគ្រោះខ្លាំងក្នុងការឆ្លង និងចម្លងមេរោគអេដស៍ ដូចជាស្ត្រីបំរើការតាមកន្លែងកំសាន្ត ស្ត្រីដែលប្រើឬចាក់គ្រឿងញៀន និងស្ត្រីដែលជាប់ពន្ធនាគារ ក្រុមស្រឡាញ់ភេទដូចគ្នា និងក្រុមយុវវ័យ[33]។ កង្វះការយល់ដឹងទូលំទូលាយ ស្តីពីមេរោគអេដស៍ ការប្រព្រឹត្តរួមភេទប្រកបដោយគ្រោះថ្នាក់ ការប្រើប្រាស់គ្រឿងស្រវឹង និងគ្រឿងញៀន រួមជាមួយនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ បានបង្កើនគ្រោះថ្នាក់ នៃការចម្លងមេរោគអេដស៍ក្នុងចំណោមក្រុមគោលដៅទាំងនេះ។

- គោលនយោបាយ និងគោលការណ៍ណែនាំគ្លីនិកសម្រាប់ឆ្លើយតបនឹងអំពើហិង្សាដែលកើតមានដោយសារដៃគូរួមភេទ និងអំពើហិង្សាផ្លូវភេទ កំពុងរៀបចំ ប៉ុន្តែនាបច្ចុប្បន្នពុំមានការផ្តល់នូវការបង្ការការចម្លងមេរោគអេដស៍ដោយមិនបង់ប្រាក់នៅឡើយទេ ក្នុងករណីដែលមានការបំពានផ្លូវភេទ ជាពិសេសក្នុងចំណោមស្ត្រីដែលប្រឈមមុខខ្ពស់នឹងការចម្លងមេរោគអេដស៍។ សេវាជំនួយផ្លូវច្បាប់សម្រាប់អ្នកផ្ទុកមេរោគអេដស៍ និងអ្នកដែលប្រឈមមុខខ្ពស់នឹងការចម្លងមេរោគអេដស៍នៅមានកម្រិតនៅឡើយ។

[33] Liu, K. L. & Chhorvann, C. (2010). Bros Khmer: Behavioral Risks On-site Serosurvey among At-risk Urban Men in Cambodia. Phnom Penh: FHI 360 & National Centre for HIV/AIDS, Dermatology and STIs. National AIDS Authority, (2012a). Cambodia Country Progress Report 2012: Monitoring the Progress towards the Implementation of the Declaration of Commitment on HIV and AIDS. Phnom Penh.

- នៅកម្ពុជា មិនទាន់មានគោលនយោបាយ ឬច្បាប់ដែលហាមឃាត់ការលក់គ្រឿងស្រវឹងដល់យុវវ័យដែលមិនទាន់គ្រប់អាយុស្របច្បាប់ នៅឡើយ។

## អនុសាសន៍សម្រាប់គោលនយោបាយ

- ពង្រឹងយុទ្ធសាស្ត្របង្កើនភាពអង់អាចដល់ស្ត្រី តាមរយៈការបង្កើនលទ្ធភាពទទួលបានព័ត៌មាន និងសេវាសុខភាពបន្តពូជ និងទូទៅនានា។
- បង្កើនប្រសិទ្ធភាព ក្នុងការធានានូវការឆ្លើយតបទៅនឹងលើផ្នត់គំនិតសង្គម ទម្លាប់ និងការប្រព្រឹត្តិនានា ដែលជាមូលហេតុនាំឱ្យមានការចម្លង និងរីករាលដាល់នៃមេរោគអេដស៍ ។
- ពង្រីក និងពង្រឹងបន្ថែមទៀតនូវលទ្ធភាពទទួលបាននូវសេវាសុខភាពបន្តពូជ សុខភាពផ្លូវភេទ និងសេវាពាក់ព័ន្ធនឹងមេរោគអេដស៍ ក្នុងចំណោមអ្នកផ្ទុកមេរោគអេដស៍ និងក្រុមស្ត្រី និងយុវតីដែលងាយរងគ្រោះ។
- ពង្រឹងសមត្ថភាពមន្ត្រីបង្គោល ក្នុងការឆ្លើយតបទៅនឹងយេនឌ័រ និងសេវាសិទ្ធិមនុស្សជាមូលដ្ឋាន ។
- ពង្រឹង និងបញ្ចូលការឆ្លើយតបទៅនឹងមេរោគអេដស៍ ទៅក្នុងកម្មវិធី គោលនយោបាយ គោលការណ៍ណែនាំ និងគម្រោងថវិកាជាផ្លូវការឱ្យបានកាន់តែទូលំទូលាយ ។
- គួរធ្វើការសិក្សាស្រាវជ្រាវ ស្តីពីទំនាក់ទំនងរវាងអំពើហិង្សាលើរាងកាយ និងផ្លូវភេទជាមួយនឹងមេរោគអេដស៍ និងជំងឺអេដស៍ ដើម្បីផ្តល់ព័ត៌មានដល់ការរៀបចំយុទ្ធសាស្ត្រឆ្លើយតបនឹងការបង្ការប្រកបដោយប្រសិទ្ធភាព។
- គួរធ្វើការសិក្សាស្រាវជ្រាវស្តីពីការឥរិយាបថស្វែងរកសេវាថែទាំសុខភាពរបស់បុរសនៅក្នុងបរិបទនៃមេរោគអេដស៍ រួមមានកត្តាដែលជំរុញឱ្យបុរសទៅទទួលសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ ដោយស្មគ្រ័ចិត្ត និងរក្សាការសម្ងាត់សេវាសុខភាពបន្តពូជ និងការចូលរួមរបស់បុរសនៅក្នុងផែនការគ្រួសារ។

## អំពើហិង្សាលើស្ត្រី និងក្មេងស្រី

នៅកម្ពុជា ស្ត្រី និងក្មេងស្រីនៅតែបន្តរងគ្រោះដោយអំពើហិង្សាផ្លូវកាយ ផ្លូវចិត្ត ផ្លូវភេទ និងផ្លូវសេដ្ឋកិច្ច ក្នុងគ្រប់ស្រទាប់វណ្ណៈ នៅក្នុងជីវិតសាធារណៈ និងឯកជន របស់ពួកគេ។ អំពើហិង្សាលើស្ត្រី និងក្មេងស្រីនៅកម្ពុជាកើតចេញពីកត្តាជាច្រើនដែលទាក់ទងនឹងឥរិយាបទ និងបទដ្ឋានសង្គមដែលផ្តល់សិទ្ធិ និងភាពអង់អាចដល់បុរសនិងក្មេងប្រុសជាងស្ត្រីនិងក្មេងស្រី។ ទម្រង់ផ្សេងៗគ្នានៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី បានកើតឡើងដោយបន្សំនៃកត្តាបុគ្គល ទំនាក់ទំនង សហគមន៍ ស្ថាប័ន និងសង្គមដែលរើសអើងទៅលើស្ត្រី និងក្មេងស្រី ដូច្នេះ អំពើហិង្សាគួរទទួលបានការឆ្លើយតបក្នុង អន្តរាគមន៍ផ្សេងៗលើគ្រប់វិស័យ។

### សមិទ្ធផលសំខាន់ៗ

តាមការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា (ឆ្នាំ២០០៥) បានបង្ហាញថា ស្ត្រីដែលធ្លាប់ទទួលរងនូវអំពើហិង្សាលើផ្លូវកាយ ផ្លូវភេទ និងផ្លូវចិត្តពីដៃគូរបស់ខ្លួន មានការថយចុះពី២៥% ក្នុងឆ្នាំ២០០០ មកត្រឹម២២% ក្នុងឆ្នាំ២០០៥[34]។ តាមទិន្នន័យឃុំសង្កាត់នៅកម្ពុជាទាក់ទងនឹងចំនួនគ្រួសារ[35] ដែលរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារដែលបានស្វែងរកជំនួយពីអាជ្ញាធរដែនដី បានបង្ហាញថា ចំនួនគ្រួសារ ដែលរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារបានថយចុះពី១,៦៣% ក្នុងឆ្នាំ២០០៦ មកត្រឹម ០,៨៨% ក្នុងឆ្នាំ២០១០[36] ។ សរុបមកការប្រៀបធៀបការអង្កេតតាមដានដែលធ្វើឡើងដោយក្រសួងកិច្ចការនារី ឆ្នាំ២០០៥ និងឆ្នាំ២០០៩ បានបង្ហាញថា ប្រជាជនភាគតិចបានទទួលស្គាល់ថា អំពើហិង្សាជាអំពើដែលអាចទទួលយកបាន និងប្រជាពលរដ្ឋភាគច្រើនបានទទួលស្គាល់ថា ការប្រព្រឹត្តអំពើហិង្សាជាការល្មើសច្បាប់[37]។

តាមការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ២០១០ បានបង្ហាញថា ស្ត្រីដែលយល់ស្របថាមានហេតុផលយ៉ាងតិចមួយដែលបុរសអាចវាយប្រពន្ធរបស់គាត់បាន

---

[34] អង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជា ឆ្នាំ២០០៥

[35] The reports to the CDB are of families not individuals and therefore not disaggregated by type of violence, perpetrator or victim

[36] ទិន្នន័យឃុំសង្កាត់ឆ្នាំ២០១៣ក្នុងគេហទំព័រ៖http://db.ncdd.gov.kh/cdbonline/home/index.castle

[37] អង្កេតតាមដានស្តីពីអំពើហិង្សាលើស្ត្រី ឆ្នាំ២០០៩ ក្រសួងកិច្ចការនារី

មានការថយចុះពី៥៥% ក្នុងឆ្នាំ២០០៥ មកត្រឹម៤៥,៧% ក្នុងឆ្នាំ២០១០[38]។ ក្របខ័ណ្ឌគោលនយោបាយក្នុងការឆ្លើយតបនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី កាន់តែមានភាពប្រសើរឡើងក្នុងរយៈពេលកន្លងមក។ ផែនការសកម្មភាពជាតិទប់ស្កាត់អំពើហិង្សាលើស្ត្រី លើកទី២ ឆ្នាំ២០១៤-២០១៨ បានរៀបចំឡើងដោយគ្របដណ្តប់លើវិស័យជាយុទ្ធសាស្ត្រ ចំនួន៥ រួមមាន៖ ១.កិច្ចការពារបឋម ២.កិច្ចការពារពហុវិស័យនិងសេវាផ្នែកច្បាប់ ៣.ច្បាប់ និងគោលនយោបាយ ៤.ការអភិវឌ្ឍសមត្ថភាព និង ៥.ការត្រួតពិនិត្យនិងវាយតម្លៃ។

ការយល់ដឹង អំពីភាពងាយរងគ្រោះរបស់ស្ត្រី និងកុមារី អំពីហិង្សា ឬបញ្ហាប្រឈមនានា និងការទទួលបាននូវកិច្ចការពារ និងសេវាសង្គម មានការកើនឡើងជាងមុន ។ កន្លងមក ការអង្កេតស្រាវជ្រាវជាច្រើនបានធ្វើឡើង និងបានជួយបង្កើនចំណេះដឹងអំពីអំពើហិង្សាលើស្ត្រីនិងក្មេងស្រីនៅកម្ពុជា។

ការយកចិត្តទុកដាក់ត្រូវបានបង្កើនក្នុងការផ្តល់នូវសេវាសង្គមពហុវិស័យ ក៏ដូចជាការគាំទ្រផ្នែកច្បាប់ ដើម្បីជួយដល់ស្ត្រី និងកុមារដែលជាជនរងគ្រោះដោយអំពើហិង្សា។

## បញ្ហាប្រឈម

- ទោះបីមានទិន្នន័យមួយចំនួន ដែលបញ្ជាក់ថា អំពើហិង្សារវាងប្តីនឹងប្រពន្ធមានការថយចុះក៏ដោយ ប៉ុន្តែអត្រាប្រេវ៉ាឡង់នៅតែមានកម្រិតខ្ពស់។ ចំណុចនេះ តម្រូវមានទិន្នន័យថ្មីៗដើម្បីស្វែងយល់បានកាន់តែច្បាស់ អំពីស្ថានភាពបច្ចុប្បន្ន។
- ទិន្នន័យដែលផ្តល់ដោយជនរងគ្រោះទាក់ទងនឹងអំពើរំលោភសេពសន្ថវៈនិងអំពើហិង្សាផ្លូវភេទនៅមានកម្រិត ប៉ុន្តែរបាយការណ៍អំពីអំពើរំលោភសេពសន្ថវៈ និងអំពើហិង្សាផ្លូវភេទទាំងនៅក្នុងគ្រួសារ និងនៅកន្លែងផ្សេងទៀត គឺមានការកើតឡើងច្រើន។ ការរំលោភបូកមានអត្រាខ្ពស់នៅកម្ពុជាធៀបនឹងប្រទេសនានាក្នុងតំបន់។
- ការបៀតបៀនផ្លូវភេទជាទូទៅច្រើនកើតមានលើស្ត្រីនៅក្នុងកន្លែងធ្វើការនិងក្នុងសហគមន៍។ ទាក់ទងនឹងការបៀតបៀននេះការងារមួយចំនួនផ្តល់នូវភាពងាយរងគ្រោះខ្ពស់ដល់ស្ត្រី

[38] អង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជា




- ការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី ឬក្មេងស្រី នៅតែមានបន្ត ប៉ុន្តែមិនទាន់មានទិន្នន័យច្បាស់លាស់នៅឡើយ។
- ផ្នត់គំនិតសង្គមនៅបន្សល់ និងគិតថាអំពើហិង្សាលើស្ត្រីអាចអត់ឱនដោយសារផ្នត់គំនិតយេនឌ័រ និងកត្តាផ្សេងៗទៀតជាច្រើនរបស់បុគ្គល ដូចជាកម្រិតទាបនៃការអប់រំ ការធ្លាប់ទទួលអំពើហិង្សាកាលនៅវ័យក្មេង និងការស្រវឹងស្រា ជាដើម។
- ជនរងគ្រោះដោយអំពើហិង្សាជាច្រើននៅមិនទាន់បានរាយការណ៍ ឬស្វែងរកជំនួយឡើយ។
- ទោះបីក្របខ័ណ្ឌច្បាប់កាន់តែមានភាពប្រសើរឡើង ប៉ុន្តែការសម្របសម្រួលរវាងអាជ្ញាធរពាក់ព័ន្ធ ជំនាញនិងសម្ភារៈស៊ើបអង្កេត និងគោលការណ៍ណែនាំក្នុងការអនុវត្តច្បាប់ នៅមានកម្រិតនៅឡើយ។

▲ **នី ផល្លា** (២៣ឆ្នាំ) បម្រើការជាប៉ូលីសជាង ២ឆ្នាំមកហើយ ដោយសារនាងចង់ឱ្យសហគមន៍របស់នាងមានសុវត្ថិភាព ។ នាងសម្រេចចិត្តចូលបម្រើការងារនេះដោយសារឪពុករបស់នាងក៏ជាប៉ូលីសដែរ ។

- វិសមភាពយេនឌ័រ កង្វះការបណ្តុះបណ្តាលនិងធនធាន គួបផ្សំនឹងកត្តានិទណ្ឌភាព គឺជាហេតុផលដែលនាំមានការដោះស្រាយបទល្មើសដោយការទូទាត់សំណង ជាពិសេសក្នុងករណីរំលោភសេពសន្ថវៈ។

- សេវាគាំទ្រសង្គម និងសេវាច្បាប់សម្រាប់ជនរងគ្រោះច្រើនមាននៅតែទីប្រជុំជន និង សេវាទាំងនោះមិនទាន់ត្រូវបានផ្តល់ជាលក្ខណៈទូលំទូលាយជាប្រព័ន្ធនៅឡើយ ហើយការផ្តល់និងការទទួលបានសេវា ក៏នៅមានកម្រិតផងដែរ។

- ស្ត្រីពិការទំនងជាទទួលរងគ្រោះច្រើនជាងគេ ដោយសារអំពើហិង្សាក្នុងគ្រួសារ ដែលប្រព្រឹត្តដោយអ្នកមិនមែនជាដៃគូ បើប្រៀបធៀបជាមួយស្ត្រីដែលមិនពិការ។ ម្យ៉ាងវិញទៀត ស្ត្រីស្រឡាញ់ស្ត្រី និងក្រុមមនុស្សកែភេទ ទំនងជាធ្លាប់ទទួល រងគ្រោះច្រើនជាងគេ ដោយសារការរើសអើង ហើយការឆ្លើយតបនៅមានកម្រិត[39]។ មួយភាគប្រាំ នៃស្ត្រីដែលបម្រើការក្នុងរោងចក្រកាត់ដេរធ្លាប់ទទួលនូវការបៀតបៀន ផ្លូវភេទនៅក្នុង និងក្បែររោងចក្ររបស់ខ្លួន[40] ហើយ៨០%នៃស្ត្រីបម្រើការជាអ្នកផ្សព្វផ្សាយស្រាបៀរ ធ្លាប់ទទួលរងនូវការបៀតបៀនដោយការប៉ះពាល់រាងកាយ[41]។ ចំពោះក្រុមងាយរងគ្រោះផ្សេងៗទៀត ពុំទាន់មានទិន្នន័យបញ្ជាក់អំពីស្ថានភាព របស់ពួកគេនៅឡើយ[42]។

- ស្ត្រីមួយចំនួនទទួលរងគ្រោះដោយសារអំពើហិង្សាផ្លូវភេទ[43] និងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ[44] ក្នុងអំឡុងរបបខ្មែរក្រហម[45] ។

[39] Ministry of Women's Affairs (2013) *National Action Plan on Violence against Women (NAPVAW) II*. Phnom Penh, Cambodia. Cambodia Center for Human Rights (2010) *Coming out in the Kingdom: Lesbian, gay and bisexual and transgender people in Cambodia.* Phnom Penh: CCHR.

[40] ILO (2012) *Action-oriented research on gender equality and the working and living conditions of garment factory workers in Cambodia.* ILO Regional Office for Asia and the Pacific.

[41] CARE Cambodia (2005) *A Report on the Situation of Beer Promotion Women in the Workplace.* Phnom Penh.

[42] CARE Cambodia ( 2005 ) A Report on the Situation of Beer Promotion Women in the Workplace. Phnom Penh.

[43] Theresa de Langis (2012), *"Moral Offenses" and Sexual Violations against Women Under the Khmer Rouge Regime*, Code 6, Phnom Penh, Cambodia

[44] Cambodian Defenders Project ( 2011 ), The Mystery of Sexual Violence under the Khmer Rouge Regime, Phnom Penh, Cambodia.

[45] De Langis, Theresa ( 2012 ) Briefing Paper on the ECCC, the Cambodian Women's Hearing, and Steps for Addressing Sexual Violence under the Khmer Rouge Regime.

## អនុសាសន៍សម្រាប់គោលនយោបាយ

- គួរពិនិត្យឡើងវិញ និងជំរុញឱ្យមានការចែងយ៉ាងច្បាស់នៅក្នុងច្បាប់ជាតិ ស្តីពីការបង្កើតប្រព័ន្ធដ៏មានប្រសិទ្ធភាព ក្នុងការរាយការណ៍ និងបញ្ជូនករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រី ។

- រៀបចំ និងអនុវត្តយុទ្ធសាស្ត្រទប់ស្កាត់បឋមពហុវិស័យ ដែលផ្តោតលើតួអង្គសំខាន់ៗ និងការផ្លាស់ប្តូរជាវិជ្ជមាននូវផ្នត់គំនិត ឥរិយាបថ អាកប្បកិរិយា ជំនឿ ការអនុវត្តន៍ប្រចាំថ្ងៃ និងបទដ្ឋានសង្គម ដែលរារាំងដល់ការផ្តល់ភាពអង់អាចដល់ស្ត្រី និងលើកកម្ពស់ការទប់ស្កាត់អំពើហិង្សាលើស្ត្រីនិងក្មេងស្រី ។

- លើកកម្ពស់កម្មវិធីសម្រាប់យុទ្ធសាស្ត្រទំនាក់ទំនងអហិង្សា និងជំនាញដោះស្រាយជម្លោះរវាងប្តីនិងប្រពន្ធ និងក្នុងក្រុមគ្រួសារ រួមទាំងទម្រង់អហិង្សា សម្រាប់ឪពុកម្តាយ និងអាណាព្យាបាលប្រើប្រាស់ក្នុងការអប់រំកុមារ។

- ផ្អែកលើបទពិសោធន៍នៃក្រុមការងារឆ្លើយតបនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ នៃក្រុមការងារបច្ចេកទេសយេនឌ័រ (TWGG-GBV) គួររៀបចំយន្តការឆ្លើយតបដោយមានការសម្របសម្រួលពហុវិស័យ ដែលក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាល អ្នកផ្តល់សេវានានា និងសង្គមស៊ីវិល ធ្វើការសម្របសម្រួល និងផ្តល់កិច្ចអន្តរាគមន៍ឱ្យបានប្រសើរជាងមុនដល់ជនរងគ្រោះ។

- គួររៀបចំស្តង់ដាអប្បរិមាសម្រាប់សេវាសង្គមផ្សេងៗ ដើម្បីបំពេញចំណុចខ្វះខាតទាំងឡាយ ក៏ដូចជាការធ្វើមានសុខដុមនីយកម្មជាមួយស្តង់ដាដែលមានស្រាប់ និងបង្កភាពងាយស្រួលសម្រាប់កុមារ ។

- បញ្ចប់ការប៉ាន់ប្រមាណ អំពីភាពជោគជ័យ និងបញ្ហាប្រឈមនៅក្នុងការឆ្លើយតបនៃប្រព័ន្ធច្បាប់ ដើម្បីផ្តល់អនុសាសន៍សម្រាប់កែលម្អច្បាប់ គោលនយោបាយ និងការអនុវត្តន៍ រួមទាំងយុទ្ធសាស្ត្រសម្រាប់ការស្វែងរកការគាំទ្រមតិទាក់ទងនឹងអំពើហិង្សាលើស្ត្រីនិងក្មេងស្រី។

- លើកកម្ពស់កិច្ចខិតខំប្រឹងប្រែងក្នុងការអភិវឌ្ឍន៍សមត្ថភាពទាក់ទងនឹងដំណើរការនៃការទប់ស្កាត់អំពើហិង្សា ច្បាប់ និងគោលនយោបាយ និងការអនុវត្តន៍ដែលផ្អែក

លើទទ្បីករ ដល់អ្នកពាក់ព័ន្ធសំខាន់ៗ ដោយរាប់បញ្ចូលទាំងអ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំសង្កាត់ នគរបាលជាតិកម្ពុជា អ្នកផ្តល់សេវាសុខភាព វេជ្ជបណ្ឌិតថៅក្រម ព្រះរាអាជ្ញា ភ្នាក់ងារនគរបាលយុត្តិធម៌ អ្នកផ្តល់សេវាពាក់ព័ន្ធ និងអ្នកពាក់ព័ន្ធដទៃទៀត។

- លើកកម្ពស់កិច្ចសម្របសម្រួលរវាងនគរបាលជាតិ អាជ្ញាធរមូលដ្ឋាន អ្នកទទួលបន្ទុកកិច្ចការនារីឃុំសង្កាត់ អ្នកផ្តល់សេវាសុខភាព អ្នកជំនាញច្បាប់ និងភ្នាក់ងារនគរបាលយុត្តិធម៌នៃក្រសួងកិច្ចការនារី មន្ត្រីបម្រើការងារសង្គម របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអង្គការដែលជាអ្នកគាំទ្រដទៃទៀត ដើម្បីផ្តល់កិច្ចការពារជាអតិបរិមា និងការថែទាំសម្រាប់ជនរងគ្រោះ និងដើម្បីលើកកម្ពស់ការផ្តន្ទាទោសជនល្មើស។
- លើកកម្ពស់ការទទួលបានសំណង (រួមទាំងការគាំទ្រផ្នែកច្បាប់) និងសេវាផ្សេងៗសម្រាប់ស្ត្រី និងក្មេងស្រីដែលងាយរងគ្រោះ ឬស្ត្រីនិងក្មេងស្រីដែលមានការលំបាកណាមួយក្នុងការទទួលបានសេវា ដូចជាស្ត្រីពិការ ស្ត្រីដែលទទួលរងអំពើហិង្សាផ្លូវភេទក្នុងរបបខ្មែរក្រហម និងស្ត្រីដទៃទៀតដែលកំពុងប្រឈមនឹងភាពងាយរងគ្រោះ ។
- លើកកម្ពស់ការសិក្សាស្រាវជ្រាវអំពីចំណេះដឹង អាកប្បកិរិយា និងការអនុវត្តន៍ជាក់ស្តែង ទាក់ទងនឹងអំពើហិង្សាលើស្ត្រីនិងក្មេងស្រី ដើម្បីស្វែងយល់អំពីឫសគល់នៃបញ្ហា និងគាំទ្រកិច្ចខិតខំប្រឹងប្រែងរួមគ្នាដើម្បីធ្វើឱ្យមានការផ្លាស់ប្តូរក្នុងសង្គម។

## ស្ត្រីក្នុងការធ្វើសេចក្តីសម្រេច ក្នុងវិស័យសាធារណៈ និងវិស័យនយោបាយ

ផ្អែកលើសន្ទស្សន៍នៃគម្លាតយេនឌ័រសកល ទាក់ទងនឹងការផ្តល់ភាពអង់អាចផ្នែកនយោបាយ កម្ពុជាស្ថិតក្នុងលំដាប់លេខ១១០ ក្នុងចំណោមប្រទេស១៤២ ក្នុងនោះកម្ពុជាទទួលបានពិន្ទុ០,០៩១ ដែលទាបជាងប្រទេសនានាដែលមានកម្រិតចំណូលប្រហាក់ប្រហែលគ្នា[46]។

រាជរដ្ឋាភិបាលកម្ពុជា មានការប្តេជ្ញាចិត្តខ្ពស់ក្នុងការលើកកម្ពស់តួនាទីស្ត្រីក្នុងការធ្វើសេចក្តីសម្រេចក្នុងវិស័យសាធារណៈនៅគ្រប់កម្រិត តាមរយៈគោលនយោបាយជាច្រើនដូចជា៖

46 World Economic Forum, Global Gender Gap Index 2014, http://www.weforum.org/issues/global-gender-gap.

- យុទ្ធសាស្ត្រចតុកោណ «ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាពនៅកម្ពុជា» (២០១៤-២០១៨)
- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម (២០០៩-២០១៣) និង (២០១៤-២០១៨)
- ផែនការយុទ្ធសាស្ត្រនារីរតនៈ ទី៣ (២០០៩-២០១៣) និងទី៤ (២០១៤-២០១៨)
- ផែនការយុទ្ធសាស្ត្រ៥ឆ្នាំរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី (២០១០-២០១៤)
- កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ២០១០-២០១៩

## សមិទ្ធផលសំខាន់ៗ

ដើម្បីលើកកម្ពស់សមភាពយេនឌ័រ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវវិធានការដាក់លាក់ជាច្រើនក្នុងការបញ្ជ្រាបយេនឌ័រ និងបង្កើនតួនាទីស្ត្រីក្នុងការធ្វើសេចក្តីសម្រេច រួមទាំងការបញ្ជ្រាបយេនឌ័រទៅក្នុងច្បាប់ គោលនយោបាយ បទដ្ឋានគតិយុត្ត និងកម្មវិធីផ្សេងៗ។ កិច្ចខិតខំប្រឹងប្រែងទាំងនេះ បាននាំមកនូវការកើនឡើងជាបណ្តើរៗនូវសមាមាត្រស្ត្រីជាអ្នកដឹកនាំ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ឧបសគ្គនានាដែលរារាំងដល់ការចូលរួមរបស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចត្រូវបានកំណត់និងចងក្រងដោយអ្នកពាក់ព័ន្ធ ដើម្បីស្វែងរកដំណោះស្រាយរួមគ្នា។

ក្នុងឆ្នាំ២០១២ ក្នុងចំណោមសមាជិកព្រឹទ្ធសភា ស្ត្រីទទួលបានអាសនៈ ១៤,៧៥[47] %។ តំណាងស្ត្រីនៅក្នុងស្ថាប័នរដ្ឋសភាបានកើនឡើងច្រើនជាង៣ដង ក្នុងរយៈពេល២ទសវត្សរ៍កន្លងមកនេះ[48]។ ចំនួនស្ត្រីក្នុងមុខតំណែងជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការមានការកើនឡើងក្នុងឆ្នាំ២០១៣[49] ធៀបនឹងអាណត្តិមុន។ ចំណែកឯ

[47] គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឆ្នាំ ២០១២-២០១៣

[48] គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឆ្នាំ ២០១២-២០១៣

[49] ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

សមាមាត្រស្ត្រី ក្នុងស្ថាប័នតុលាការក៏មានការកើនឡើងផងដែរ ចាប់ពីឆ្នាំ២០០៨មក[50]។ អភិបាលរងជាស្ត្រី នៃរាជធានី ខេត្ត កើនឡើង២០% ដែលលើសពីការរំពឹងទុកក្នុងគោលដៅទី៣ នៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា។ ស្ត្រីជាសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត មានការកើនឡើងពី១០% ក្នុងឆ្នាំ២០០៩ ដល់១៣,២៣%ក្នុងឆ្នាំ២០១៤។ ចំណែកឯស្ត្រីជាសមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ មានការកើនឡើងពី១២,២៣% ក្នុងឆ្នាំ២០០៩ ដល់១៣,៨៥% ក្នុងឆ្នាំ២០១៤។ អត្រាស្ត្រីជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ កើនឡើងពី១៥,១% ក្នុងឆ្នាំ២០០៧ ដល់ ១៧,៧៨% ក្នុងឆ្នាំ២០១២[51]។

សមាមាត្រស្ត្រីជាមន្ត្រីរាជការកើនឡើងពី៣២% ក្នុងឆ្នាំ២០០៧ ដល់៣៧% ក្នុងឆ្នាំ២០១៣[52]។ ក្រសួង ស្ថាប័នចំនួន២០ ក្នុងចំណោមក្រសួង ស្ថាប័នទាំង២៧ បានរាយការណ៍អំពីការកើនឡើងនូវចំនួនមន្ត្រីរាជការជាស្ត្រី ពី០,២៧ %ក្នុងឆ្នាំ២០០៨ ដល់៧,៩ %ឆ្នាំ២០១៣[53]។ នៅសាលាភូមិន្ទរដ្ឋបាល សមាមាត្រស្ត្រីដែលបានចូលរៀនមានការកើនឡើង ជាពិសេសក្នុងកម្មវិធីបណ្តុះបណ្តាលដំបូង[54]។

## បញ្ហាប្រឈម

- ចំនួនស្ត្រីដែលមានតួនាទីធ្វើសេចក្តីសម្រេចនៅកម្ពុជាមានកម្រិត នៅក្នុងវិស័យនយោបាយ វិស័យសាធារណៈ និងតុលាការ។
- ការរើសអើងចំពោះស្ត្រីនៅបន្តកើតមាន និងជាឧបសគ្គដល់ការទទួលបានការតែងតាំងក្នុងមុខតំណែងនានារបស់ស្ត្រី។នា។
- ស្ត្រីមានចំនួនច្រើននៅក្នុងការងារដែលខ្លួនធ្លាប់ធ្វើជាប្រពៃណី និងនៅក្នុងតួនាទីកម្រិតទាបតាមក្រសួងស្ថាប័ន។
- បុរសមានចំនួនច្រើនក្នុងតួនាទីធ្វើសេចក្តីសម្រេចនៅតាមរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

---

50 តារាងស្ថិតិមន្ត្រីរាជការស៊ីវិលដែលមានមុខតំណែងចាប់ពីថ្នាក់អគ្គនាយករហូតដល់ថ្នាក់ការិយាល័យតាមក្រុង/ស្រុក/ខណ្ឌ និងថ្នាក់ស្មើ ឆ្នាំ ២០១៣, ក្រសួងមុខងារសាធារណៈ, ថ្ងៃទី ៣១ ខែមករា ឆ្នាំ ២០១៤

51 គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឆ្នាំ ២០១២

52 តារាងស្ថិតិមន្ត្រីរាជការស៊ីវិលដែលមានមុខតំណែងចាប់ពីថ្នាក់អគ្គនាយករហូតដល់ថ្នាក់ការិយាល័យតាមក្រុង/ស្រុក/ខណ្ឌ និងថ្នាក់ស្មើ ឆ្នាំ ២០១៣, ក្រសួងមុខងារសាធារណៈ, ថ្ងៃទី ៣១ ខែមករា ឆ្នាំ ២០១៤

53 Ibid.

54 សាលាភូមិន្ទរដ្ឋបាល ឆ្នាំ ២០១៣




▲ **លោកស្រី ទេព ព្រហ្មមុនី** (៥៥ឆ្នាំ) បានក្លាយជាចៅសង្កាត់នាដើមឆ្នាំ២០១៤ និងបានសាងកេរ្តិ៍ឈ្មោះយ៉ាងល្អក្នុងសហគមន៍នេះ ។ គាត់បានចូលបម្រើការជាមន្ត្រីរាជការតាំងពីឆ្នាំ១៩៨៦ ។

- ស្ត្រីនៅថ្នាក់ក្រោមជាតិ ជួបប្រទះបញ្ហាប្រឈមជាច្រើន ក្នុងការចូលរួមក្នុងការធ្វើសេចក្តីសម្រេច ក្នុងវិស័យសាធារណៈ និងនយោបាយ ជាពិសេសការរើសអើងនៅកន្លែងធ្វើការ។
- កង្វះវិធានការបណ្តោះអាសន្ន ដើម្បី «ពន្លឿន» ការចូលរួមរបស់ស្ត្រីក្នុងតួនាទីធ្វើសេចក្តីសម្រេចក្នុងវិស័យសាធារណៈ និងនយោបាយ ។
- គណបក្សនយោបាយមានតួនាទីសំខាន់ ក្នុងការជំរុញឱ្យមានតំណាងស្ត្រីក្នុងការធ្វើសេចក្តី សម្រេច ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។
- កត្តាមួយចំនួននៅក្នុងប្រព័ន្ធបោះឆ្នោតអាចជួយជំរុញឱកាសរបស់ស្ត្រីក្នុងការចូលរួមធ្វើសេចក្តីសម្រេច ដូចជាការជ្រើសរើសបេក្ខជន ការដាក់ស្ត្រីនៅលេខរៀងលើនៃបញ្ជីគណបក្ស និងការកំណត់កម្រិតចំនួនសម្រាប់ស្ត្រី ជាដើម ។

- ការលើកកម្ពស់សមភាពយេនឌ័រក្នុងតួនាទីធ្វើសេចក្តីសម្រេចនៅតែជាការទទួលខុសត្រូវ ដ៏ធំធេងរបស់ស្ត្រី ទោះបីជាការងារនេះជាការទទួលខុសត្រូវរួមគ្នារវាងស្ត្រីនិងបុរសក៏ដោយ។ មិនទាន់មានកិច្ចសហការរវាងដៃគូពាក់ព័ន្ធ ក្នុងការរៀបចំក្របខ័ណ្ឌ ឬកម្មវិធីរួម ក្នុងការលើក កម្ពស់ការចូលរួមរបស់ស្ត្រី ក្នុងថ្នាក់ធ្វើសេចក្តីសម្រេចនៅឡើយ ។
- ស្ត្រីមានចំនួនច្រើនក្នុងមុខតំណែងទាបនៅក្នុងវិស័យសាធារណៈ ចំណែកឯក្នុងមុខតំណែងគ្រប់គ្រង ស្ត្រីភាគច្រើនជាអនុប្រធាន ។
- មិនទាន់មានកិច្ចសហការរវាងដៃគូពាក់ព័ន្ធ ក្នុងការរៀបចំក្របខ័ណ្ឌ ឬកម្មវិធីរួមសម្រាប់លើកកម្ពស់ការចូលរួមរបស់ថ្នាក់ឡើយ។

## អនុសាសន៍សម្រាប់គោលនយោបាយ

- គួររៀបចំឱ្យមានយុទ្ធនាការស្វែងរកការគាំទ្រដែលមានប្រសិទ្ធភាព និងនិរន្តរភាព ដើម្បីមានការចូលរួមពីអ្នកពាក់ព័ន្ធសំខាន់ៗ ក្នុងការតាក់តែងច្បាប់ និងគោលនយោបាយដែលឆ្លើយតបនឹងយេនឌ័រ និងបង្កើនតំណាងស្ត្រី ក្នុងស្ថាប័ននីតិប្បញ្ញត្តិ។
- ពង្រីកបរិយាកាសគាំទ្រកាន់តែប្រសើរសម្រាប់ស្ត្រីនៅស្ថាប័ននីតិប្រតិបត្តិ។
- រៀបចំ និងធ្វើឱ្យមាននិរន្តរភាពនូវយុទ្ធនាការស្វែងរកការគាំទ្រប្រកបដោយប្រសិទ្ធភាព ដើម្បីអភិវឌ្ឍសមត្ថភាព និងតែងតាំងស្ត្រីឱ្យបានកាន់តែច្រើន និងលើកទឹកចិត្តចៅក្រម ព្រះរាជអាជ្ញា និង មេធាវីជាស្ត្រី ឱ្យចូលរួមក្នុងផ្នែកតុលាការ។
- បន្តស្វែងរកការគាំទ្រមតិជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីបង្កើនចំនួនស្ត្រីក្នុងតួនាទីជាអ្នកដឹកនាំនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជាពិសេសនៅតាមមន្ទីរអង្គភាពវិស័យ ។
- បន្តសម្របសម្រួលក្នុងការរៀបចំ និងពង្រឹងបណ្តាញថ្នាក់ដឹកនាំស្ត្រីនៅថ្នាក់ក្រោមជាតិ ។
- សម្របសម្រួល និងរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍសមត្ថភាពសម្រាប់ស្ត្រីជាថ្នាក់ដឹកនាំដែលជាប់ឆ្នោត និងដែលត្រូវបានតែងតាំងនៅថ្នាក់ក្រោមជាតិ ស្របជាមួយនឹងអាទិភាពជាយុទ្ធសាស្ត្រ។

- នៅក្នុងសេវាសាធារណៈ តម្រូវឱ្យមានវិធានការពិសេសរួមគ្នា (ទាំងបណ្តោះអាសន្ន និងអចិន្ត្រៃយ៍) ក្នុងការដោះស្រាយបញ្ហាវិសមភាពយេនឌ័រ និងពន្លឿនកំណើនការចូលរួមរបស់ស្ត្រីក្នុងវិស័យសាធារណៈ។

- គាំទ្រដល់ក្រសួងមុខងារសាធារណៈ ក្នុងការបង្កើតយន្តការតាមដានទៀងទាត់ក្នុងការជ្រើសរើស និងតម្លើងតួនាទីរបស់ស្ត្រី និងបុរសនៅក្នុងវិស័យសាធារណៈ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

- សហការជាមួយក្រសួងមុខងារសាធារណៈ និងសាលាភូមិន្ទរដ្ឋបាល ក្នុងការរៀបចំ និងអនុវត្តវិធានការដាក់លាក់ជាវិជ្ជមាន ដើម្បីបង្កើនសមាមាត្រសិស្ស និងកម្មសិក្សាការីជានារី នៅសាលាភូមិន្ទរដ្ឋបាល។

- ជំរុញឱ្យមានការយកចិត្តទុកដាក់ជាពិសេសដល់ស្ត្រីនៅគ្រប់សកម្មភាពនៃការអភិវឌ្ឍន៍សមត្ថភាព ។

- ស្វែងរកការគាំទ្រមតិប្រកបដោយប្រសិទ្ធភាពពីអ្នកតាក់តែងច្បាប់ និងអ្នកធ្វើសេចក្តីសម្រេចក្នុងការកំណត់របៀបវារៈគោលនយោបាយ ដើម្បីបង្កើនការគាំទ្រដល់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេច។

- សហការជាមួយបណ្តាញយុវជន ដើម្បីលើកកម្ពស់ការចូលរួមរបស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចក្នុងវិស័យសាធារណៈ និងជួយជ្រោមជ្រែងដល់យុវជនដែលមានសក្តានុពលជាអ្នកដឹកនាំនៅពេលអនាគត។

- ជំរុញការចូលរួមរបស់ក្រុមស្ត្រីងាយរងគ្រោះ ជាពិសេសស្ត្រីពិការ ស្ត្រីជនជាតិដើមភាគតិច និងស្ត្រីក្នុងក្រុមសាសនាផ្សេងៗ ទៅក្នុងកិច្ចការងារនយោបាយ ការធ្វើសេចក្តីសម្រេច និងកិច្ចការងារសាធារណៈ ។ លើសពីនេះ វិធានការពិសេសនានាដែលនៅជាធរមានសម្រាប់ក្រុមងាយរងគ្រោះ ដូចជាកូតាសម្រាប់ជនពិការ ត្រូវមានលក្ខណៈសមភាពយេនឌ័រ (៥០/៥០)ផងដែរ។

## យេនឌ័រ និងការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍន៍បៃតង និងការគ្រប់គ្រងគ្រោះមហន្តរាយ

ការប្រែប្រួលអាកាសធាតុ បានក្លាយជាបញ្ហាសំខាន់ថ្មីមួយសម្រាប់ការអភិវឌ្ឍន៍ប្រទេសកម្ពុជា។ ភាគច្រើននៃការពិភាក្សាលើគោលនយោបាយ បានផ្តោតជាសំខាន់ទៅក្នុងបរិបទ «និរន្តរភាពបរិស្ថាន និងការអភិវឌ្ឍន៍បៃតង» ហើយដែលប្រធានបទទាំងបីនេះមាន

ទំនាក់ទំនងប្រទាក់ក្រឡាគ្នាទៅវិញទៅមក។ ក្រសួងកិច្ចការនារីបាននិងកំពុងចាប់ផ្តើមផ្តោតការយកចិត្តទុកដាក់ជាពិសេសលើផ្នែកយេនឌ័រ ពោលគឺតួនាទីរបស់ស្ត្រីក្នុងការប្រឈមមុខជាមួយការប្រែប្រួលអាកាសធាតុ និងបរិស្ថានធម្មជាតិ។

ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមកលើប្រទេសកម្ពុជាមានដូចជា គ្រោះរាំងស្ងួតរយៈពេលវែង ទឹកជំនន់ ការកើនឡើងនៃសីតុណ្ហភាព និងការប្រែប្រួលរដូវកាល រួមទាំងខ្យល់ព្យុះធំៗដែលមិនអាចស្មានដល់ ដែលទាំងនេះបានប៉ះពាល់ជាពិសេសដល់វិស័យកសិកម្ម និងប្រជាជនភាគច្រើននៅតាមជនបទ។

ទន្ទឹមនឹងនេះ ការគ្រប់គ្រងធនធានធម្មជាតិមិនបានល្អ ដូចជាការកាប់បំផ្លាញព្រៃធម្មជាតិដែលគ្មានការត្រួតពិនិត្យត្រឹមត្រូវ បានធ្វើមានការប៉ះពាល់យ៉ាងខ្លាំងដល់ និរន្តរភាពបរិស្ថាន និងភាពធន់របស់ធម្មជាតិទៅនឹងគ្រោះមហន្តរាយ។ ទាំងនេះបានបង្កនូវការលំបាកយ៉ាងខ្លាំងដល់ប្រជាជនក្រីក្រនៅតាមទីប្រជុំជន និងជនបទដែលភាគច្រើនគឺជាស្ត្រី និងកុមារ។

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាកំពុងពិនិត្យទៅលើ ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ពោលគឺបង្កើនភាពធន់ និងកាត់បន្ថយភាពងាយរងគ្រោះ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ ពោលគឺការនាំឆ្ពោះទៅរកសង្គមដែលបញ្ចេញកាបូនតិច និងកាត់បន្ថយ ឬ ទប់ស្កាត់ការបញ្ចេញ «ឧស្ម័នផ្ទះកញ្ចក់»។

ស្ត្រីជនបទពឹងផ្អែកជាពិសេសលើធនធានធម្មជាតិនៅក្នុងតំបន់របស់ខ្លួន ហើយមានតួនាទីក្នុងការស្វែងរកទឹកប្រើប្រាស់ ចំណីអាហារ និងថាមពលសម្រាប់ចម្អិន ព្រមទាំងការងារផ្ទះសម្បែងផ្សេងៗទៀត។ គ្រោះទឹកជំនន់ ភ្លៀងធ្លាក់មិនទៀងទាត់ និងការកាប់ព្រៃឈើ បានផ្តល់ផលប៉ះពាល់ដល់ស្ត្រីខុសប្លែកពីបុរស។ ដូចគ្នានេះដែរ ការប្រែប្រួលអាកាសធាតុ មានការប៉ះពាល់ជាអវិជ្ជមានយ៉ាងខ្លាំងដល់សុខភាពស្ត្រី។ ការប្រែប្រួលអាកាសធាតុប៉ះពាល់យ៉ាងច្រើនផងដែរដល់សង្គមនិងសុខភាព តាមរយៈកត្តាផ្សេងៗដូចជាខ្យល់អាកាស ទឹកពិសារ សន្តិសុខស្បៀង និងទីជម្រក។

ម្យ៉ាងទៀត ស្ត្រីដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា ដូចជាការចូលរួមកម្លាំងក្នុងទីផ្សារពលកម្ម និងការប្រកបរបរផ្ទាល់ខ្លួនជាដើម។ ដូចនេះ ជីវភាពស្ត្រីនិងគ្រួសាររបស់គាត់ដែលអាស្រ័យលើការងារ និងរបរផ្ទាល់ខ្លួន ត្រូវរងផលប៉ះពាល់ជាពិសេសអ្នកដែលពឹងផ្អែកលើវិស័យកសិកម្ម និងឧស្សាហកម្មជនបទ។



▲ **ហេង ភាព (៤១ឆ្នាំ)** ជាកសិករនៅស្រុក អរិយក្សត្រ ខេត្តកណ្តាល ។ ពីមុន អ្នកស្រីគឺជាអ្នកត្បាញ តែដោយសារមិនសូវចំណេញ ក៏ប្តូរមកស៊ីឈ្នួលធ្វើស្រែឱ្យគេវិញ គ្រាន់បានកម្រៃខ្លះ ។

ស្ត្រីនៅមានឱកាសជាច្រើនក្នុងការចូលរួមក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ ដូចជា ការកាត់បន្ថយនូវឧស្ម័នផ្ទះកញ្ចក់ និងការអភិវឌ្ឍបៃតងជាដើម។ ដូចនេះ ការពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី និងការប្រែប្រួលអាកាសធាតុ មានទំនាក់ទំនងគ្នាទៅវិញទៅមកដោយផ្ទាល់ ហើយអាចបង្កើតនូវឱកាសឆ្ពោះទៅសង្គមមួយដែលបញ្ចេញកាបូនតិច[55]។ ឱកាសទាំងនេះមានដូចជាការជំរុញនូវការប្រើប្រាស់ថាមពលកកើតឡើងវិញ ដែលត្រូវបានគេគិតថាជាបច្ចេកវិទ្យាដ៏សំខាន់នៅក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ។ ដោយសារ សម្ភារៈប្រើប្រាស់ ឬឧបករណ៍កសិកម្ម និងឧស្សាហកម្មតាមផ្ទះប្រើប្រាស់ថាមពលអគ្គិសនីជាចំបង ដូចនេះស្ត្រីមានតួនាទីសំខាន់ណាស់នៅក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ។

សមាសធាតុសំខាន់ៗស្តីពីយេនឌ័រនិងការប្រែប្រួលអាកាសធាតុ ដែលមាននៅក្នុងផែនការយុទ្ធសាស្ត្រស្តីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុ

55 http://www.unep.org/climatechange/mitigation/

២០១៣-២០២៣ និងផែនការសកម្មភាពស្តីពី យេនឌ័រ និងការប្រែប្រួលអាកាសធាតុ ឆ្នាំ២០១៤-២០១៨ រួមមាន៖

- ជំរុញការចូលរួមរបស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេច ស្តីពីការបន្សាំនិងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយធម្មជាតិនៅគ្រប់កម្រិត និងគ្រប់វិស័យ។
- ធ្វើការប៉ាន់ប្រមាណសមត្ថភាពក្រសួង ស្ថាប័នពាក់ព័ន្ធ ស្តីពីយេនឌ័រនិងការប្រែប្រួលអាកាសធាតុ និងការរៀបចំវិធីសាស្រ្តសម្រាប់ការបន្សាំនិងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយ។
- លើកកម្ពស់នៃការយល់ដឹងស្តីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុដល់ថ្នាក់ដឹកនាំ មន្រ្តី របស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ទាំងថ្នាក់ជាតិ និងក្រោមជាតិ និងភាគីពាក់ព័ន្ធផ្សេងៗទៀត។
- អនុវត្តគម្រោងសាកល្បងក្នុងការបន្សាំ និងកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងភាពអង់អាចដល់ស្រ្តី ដូចជាលើកកម្ពស់ជីវភាពរស់នៅ សន្តិសុខស្បៀង អាហារូបត្ថម្ភ សុខភាពនិងអនាម័យ ការទទួលបានទឹកស្អាត ការគ្រប់គ្រងកាកសំណល់ ការទទួលបានព័ត៌មាន និងការបង្កើតក្រុមគាំទ្រ ។
- ស្រាវជ្រាវ និងចងក្រងទិន្នន័យ និងព័ត៌មានស្តីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុ ។
- ចងក្រង និងផ្សព្វផ្សាយការអនុវត្ត និងបទពិសោធន៍ល្អៗស្តីពីយេនឌ័រនិងការប្រែប្រួលអាកាសធាតុសម្រាប់បង្កើនការរៀនសូត្រ និងការចែករំលែកដល់អ្នកពាក់ព័ន្ធ។
- ផែនការសកម្មភាពស្តីពីយេនឌ័រនិងការប្រែប្រួលអាកាសធាតុ (២០១៤-២០១៨) មានគោលបំណងប្រែក្លាយអនុសាសន៍នៅក្នុងផែនការយុទ្ធសាស្រ្តស្តីពីយេនឌ័រនិងការប្រែប្រួលអាកាសធាតុឱ្យទៅជាការអនុវត្តជាក់ស្តែង ដោយផ្តោតទៅលើស្រ្តី និងក្រុមជនងាយរងគ្រោះផ្សេងទៀត ដូចជាកុមារ មនុស្សចាស់ ជនពិការ និងជនជាតិដើមភាគតិច តាមរយៈវិធានការអភិវឌ្ឍន៍សមត្ថភាពសម្រាប់ស្រ្តីក្នុងកិច្ចពិគ្រោះយោបល់លើគោលនយោបាយ ការដឹកនាំ ការបង្កើតរបរចិញ្ចឹមជីវិតការអភិវឌ្ឍន៍បៃតង និងការបង្កើនសមត្ថភាពបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ

ក្នុងសហគមន៍។ ផែនការសកម្មភាពស្តីពីយេនឌ័រនិងការប្រែប្រួលអាកាសធាតុផ្អែកលើយុទ្ធសាស្ត្រចំនួនបីគឺ៖ ១) ពង្រឹងសមត្ថភាពស្ថាប័ន និងការសម្របសម្រួលអន្តរវិស័យដើម្បីកាត់បន្ថយភាពងាយរងគ្រោះរបស់ស្ត្រី ក្រុមស្ត្រីដែលងាយរងគ្រោះពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ២) បង្កើនសមត្ថភាព និងចំណេះដឹងស្តីពីការឆ្លើយតបទៅនឹងយេនឌ័រនិងការប្រែប្រួលអាកាសធាតុ ៣) លើកកម្ពស់ការឆ្លើយតបទៅនឹងបញ្ហាយេនឌ័រនៅក្នុងអន្តរាគមន៍នានាទាក់ទងនឹងការប្រែប្រួលអាកាសធាតុ ។

## អនុសាសន៍សម្រាប់គោលនយោបាយ

- លើកទឹកចិត្តឱ្យស្ត្រី ចូលរួមក្នុងកម្មវិធីអនុវត្តសកម្មភាពសេដ្ឋកិច្ចបៃតង នៅក្នុងវិស័យកសិកម្ម និងឧស្សាហកម្មធុនតូច រួមទាំងបង្កើនការប្រើប្រាស់ថាមពលកកើតឡើងវិញ ដូចជាថាមពលខ្យល់ ព្រះអាទិត្យ និងជីវម៉ាសជាដើម។
- ជំរុញស្ត្រីជាសហគ្រិនប្រើប្រាស់ព័ត៌មាន ទំនាក់ទំនង និងបច្ចេកវិទ្យា ក្នុងការផ្សព្វផ្សាយព័ត៌មាន និងចំណេះដឹងដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុនៅតំបន់ជនបទ។
- បន្តបញ្ជ្រាបយេនឌ័រក្នុងការគ្រប់គ្រងគ្រោះថ្នាក់ធម្មជាតិ និងក្នុងគោលនយោបាយ និងកម្មវិធីនានាទាក់ទងនឹងការប្រែប្រួលអាកាសធាតុ។
- ក្នុងអំឡុងពេលនៃគ្រោះមហន្តរាយធម្មជាតិ និងគ្រោះថ្នាក់ទាក់ទងនឹងបម្រែបម្រួលអាកាសធាតុ ត្រូវបន្តការយកចិត្តទុកដាក់ជាពិសេសចំពោះក្រុមស្ត្រី និងកុមារីងាយរងគ្រោះ ដូចជាស្ត្រីវ័យចំណាស់ ស្ត្រី និងកុមារីពិការ ស្ត្រី និងកុមារីមានផ្ទុកមេរោគអេដស៍/ជម្ងឺអេដស៍ ស្ត្រី និង កុមារីជនជាតិដើមភាគតិច និងស្ត្រី និងកុមារីរស់នៅតំបន់ដាច់ស្រយាល។
- វិធានការផ្លូវច្បាប់ គោលនយោបាយ កម្មវិធី និងយុទ្ធសាស្ត្រស្តីពីនិរន្តរភាពបរិស្ថានត្រូវមានលក្ខណៈឆ្លើយតបទៅនឹងតម្រូវការរបស់ក្រុមស្ត្រី និងកុមារីងាយរងគ្រោះទាំងនោះ។



**ជឿន គឹមហេង (២៤ឆ្នាំ)** ជាអ្នកបកប្រែព័ត៌មានអន្តរជាតិមកជាភាសាខ្មែរនៅស្ថានីយទូរទស្សន៍ជាតិកម្ពុជា ។ នាងវារឡើងលើកាំជណ្ដើរជារៀងរាល់ថ្ងៃ ដោយសារគ្មានផ្លូវជម្រាល ប៉ុន្តែ នាងមិនដែលខ្វល់នោះទេ ។ នាងធ្វើការនេះ ដោយសារ នាងគិតថា នាងអាចធ្វើវាបាន ។

ក្រសួងកិច្ចការនារី
ផ្លូវទ្រុងមាន់ ភូមិដំណាក់ធំ ៣ សង្កាត់ស្ទឹងមានជ័យ
ក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ហ្វាក់ : (+៨៥៥) ២៣ ៨៨០ ៧៣៧
អ៊ីម៉ែល : mwa@online.com.kh
វេបសាយ : www.mowa.gov.kh
ហ្វេសប៊ុក : www.facebook.com/mowa.gov.kh